អគ្គនាយកដ្ឋានកសិកម្ម

នាយកដ្ឋានផលិតកម្ម
និងបសុព្យាបាល

គម្រោងអភិវឌ្ឍន៍កសិកម្ម
និងជំរុញកំណើនសេដ្ឋកិច្ច

# បច្ចេកទេសចិញ្ចឹមមាន់ ជ្រូក និងគោ ជាលក្ខណៈគ្រួសារ



រៀបចំដោយ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
សហការជាមួយ អគ្គនាយកដ្ឋានកសិកម្ម

ខែកក្កដា ឆ្នាំ២០១៣



រៀបចំដោយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល សហការជាមួយ អគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភថវិកាដោយ គម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច

រក្សាសិទ្ធិគ្រប់យ៉ាងដោយអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រាល់សំណើសុំផលិតត្រូវសុំការអនុញ្ញាតពីអគ្គនាយកដ្ឋានកសិកម្ម

# សៀវភៅបច្ចេកទេស
# ចិញ្ចឹមមាន់ ជ្រូក និងគោ
# ជាលក្ខណៈគ្រួសារ

## រៀបចំដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល
## សហការជាមួយអគ្គនាយកដ្ឋានកសិកម្ម
## ខែកក្កដា ឆ្នាំ២០១៣

ឧបត្ថម្ភការបោះពុម្ពចំនួន ១០០០០ ក្បាល

ដោយគម្រោងអភិវឌ្ឍន៍កសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច ( PADEE )

រក្សាសិទ្ធិគ្រប់យ៉ាងដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលនិងអគ្គនាយកដ្ឋានកសិកម្ម

## **អ្នករៀបរៀង**

| | |
|---|---|
| បណ្ឌិត **សរ ចិត្រា** | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| បណ្ឌិត **អ៊ុក សាទិន** | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| លោក **ម៉ម សុមុនី** | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| លោក **ជា សុខុម** | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |
| លោក **ឃី យូខេង** | នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល |

## **អ្នកផ្តល់យោបល់កែសម្រួល**

១. ឯកឧត្តម **សូ ខនឫទ្ធីគុណា** អគ្គនាយកដ្ឋានកសិកម្ម

២. ឯកឧត្តម **កៅ ផល** នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

៣. លោក **ប៉ែន ខុង** អគ្គនាយកដ្ឋានកសិកម្ម

៤. លោក **ខិន ឆាយ** នាយកដ្ឋានដំណាំស្រូវ

៥. តំណាងវិទ្យាស្ថាន និងការិយាល័យនៅក្រោមនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល

៦. តំណាងមន្ទីរកសិកម្មខេត្តចំនួន ៥: ព្រៃវែង ស្វាយរៀង តាកែវ កំពត និងខេត្តកណ្តាល។

៧. លោក **ផាន ឆុង** រចនាក្រាហ្វិច នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

## មាតិកា ទំព័រ


អារម្ភកថា........................................................................................................v

**ផ្នែកទី១ : បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ**

លក្ខណៈល្អប្រសើរនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក..........................................................៣
គុណសម្បត្តិនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក.................................................................៤
ជំពូក ១ : ទ្រុងសម្រាប់ចិញ្ចឹមមាន់ .........................................................................៥
១. ទំហំទីកន្លែងរស់នៅ ........................................................................................៥
២. ទ្រុងសម្រាប់ថែរក្សាកូនមាន់...............................................................................៥
៣. ទ្រុងមាន់ធំ.....................................................................................................៦
៤. ស្នូកចំណី និងស្នូកទឹក ....................................................................................៧
ជំពូក ២ : ពូជ និងការបង្កាត់ពូជមាន់ ......................................................................៩
១. ការបង្កកំណើត ...............................................................................................៩
២. ការបង្កជាស៊ុត និងការក្រាប ..............................................................................៩
៣. ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់ .........................................................................៩
៤. ការភ្ញាស់ស៊ុត និងការញាស់ ...............................................................................៩
៥. ការជ្រើសកូនមាន់មកចិញ្ចឹម ...............................................................................១១
៦. ការជ្រើសរើសបាមាន់ ......................................................................................១១
៧. ការជ្រើសរើសមេមាន់.......................................................................................១២
៨. ការបង្កាត់ពូជមាន់ ...........................................................................................១២
ជំពូក ៣ : វដ្តផលិតកម្មមាន់ និងការថែរក្សាកូនមាន់ ....................................................១៤
១. វដ្តផលិតកម្មមាន់ ...........................................................................................១៤
២. ការថែរក្សាកូនមាន់ទើបញាស់ .............................................................................១៤
ជំពូក ៤ : ការកែលំអពូជ និងការជម្រុះមាន់ ..............................................................១៧
១. ការបង្កាត់ពូជ .................................................................................................១៧
២. ការជម្រុះ .......................................................................................................១៧
ជំពូក ៥ : ចំណីអាហារសម្រាប់មាន់ .........................................................................១៨
១. ការផ្តល់ចំណី .................................................................................................១៨
២. វត្ថុធាតុដើមសម្រាប់ផ្សំចំណី ..............................................................................១៨
៣. សមាសធាតុចំណីសំបូរជាតិសាច់ (ប្រូតេអ៊ីន) ..........................................................១៩
៤. សមាសធាតុចំណីសំបូរថាមពល ...........................................................................២០
៥. សមាសធាតុចំណីសំបូរជីវជាតិរ៉ែ.............................................................................២០
៦. សមាសធាតុចំណីសំបូរវីតាមីន ............................................................................២១

៧. ការចិញ្ចឹមជន្លេនក្រហម សម្រាប់ជាចំណីបំប៉ន ........................................................២១
៨. ការផលិតកូនដង្កូវ .........................................................................................................២៣
ជំពូក ៦ : ការផ្តល់ចំណី និងទឹកដល់មាន់ ...........................................................................២៤
១. ការផ្តល់ចំណីដល់មេ បា និងមាន់ធំ ...................................................................................២៤
២. ការផ្តល់ចំណីដល់កូនមាន់ ..................................................................................................២៤
៣. ការផ្តល់ទឹក ......................................................................................................................២៥
ជំពូក ៧ : ជីវសុវត្ថិភាព និងការធ្វើអនាម័យ..........................................................................២៦
១. អនាម័យកន្លែងចិញ្ចឹម .......................................................................................................២៦
២. អនាម័យចំណីអាហារ និងទឹក..............................................................................................២៦
៣. ការរៀបចំចិញ្ចឹមមាន់ .........................................................................................................២៦
៤. អនាម័យលើការឆ្លងពីក្រៅ និងឧបករណ៍ចិញ្ចឹម .....................................................................២៧
ជំពូក ៨ : ការការពារជម្ងឺមាន់ .........................................................................................២៨
១. ស្ថានភាពសុខភាព .............................................................................................................២៨
២. លក្ខណៈរបស់មាន់ ..............................................................................................................២៨
៣. ជម្ងឺដែលច្រើនកើតមានលើមាន់ ..........................................................................................៣០
៤. លក្ខណៈទូទៅរបស់វ៉ាក់សាំង ...............................................................................................៤១

## ផ្នែកទី២ : បច្ចេកទេសចិញ្ចឹមជ្រូកជាលក្ខណៈគ្រួសារ

ជំពូក ១ : ពូជជ្រូក និងការជ្រើសរើសពូជ.............................................................................៤៥
១. ពូជ ................................................................................................................................៤៥
២. ការជ្រើសរើសពូជ ..............................................................................................................៤៦
ជំពូក ២ : ការសាងសង់ទ្រុង ...........................................................................................៤៨
១. ទីតាំង និងទំហំ ...............................................................................................................៤៨
២. កម្រាល និងទីធ្លា ..............................................................................................................៤៨
៣. ដំបូល ..............................................................................................................................៤៩
ជំពូក ៣ : ការផ្តល់ចំណី និងទឹក .....................................................................................៥០
១. ការផ្តល់ចំណី ....................................................................................................................៥០
២. សមាសធាតុសំខាន់ៗក្នុងចំណី ..............................................................................................៥១
៣. ការផ្តល់ទឹក.......................................................................................................................៥២
ជំពូក ៤ : ការបង្កាត់ពូជ ..................................................................................................៥៤
១. ជ្រូកបាក្មេង និងជ្រូកមេក្រមុំ ...............................................................................................៥៤
២. មេជ្រូកផ្កាច់ដោះ ...............................................................................................................៥៤
៣. វដ្តនៃការរកឈ្មោល ............................................................................................................៥៤
ជំពូក ៥ : ការថែទាំមេជ្រូក និងកូន .................................................................................៥៦

១. មេផើម ........................................................................................................៥៦
២. មេកើតកូន ....................................................................................................៥៧
ជំពូក ៦ : ការថែទាំកូនផ្ដាច់ដោះ ជ្រូកជំទង់ និងជ្រូកសាច់ ..........................................៦៥
១. ការផ្ដាច់ដោះ ...................................................................................................៦៥
២. ជ្រូកជំទង់ និងជ្រូកសាច់........................................................................................៦៨
ជំពូក ៧ : ការធ្វើអនាម័យ និងវិធានការការពារសុខភាពសត្វ ...........................................៦៩
១. សកម្មភាពទូទៅ ..................................................................................................៦៩
២. ការការពារជំងឺដោយការដាក់ដោយឡែក ...................................................................៦៩
៣. ការណែនាំលើការប្រើប្រាស់វ៉ាក់សាំង ........................................................................៦៩
ជំពូក ៨ : ជំងឺដែលច្រើនកើតមានលើមេជ្រូក និងកូនជ្រូក .................................................៧០
១. រលាកស្បែក .......................................................................................................៧០
២. ជំងឺកញ្ជ្រិល ......................................................................................................៧០
៣. អង្គែ ...............................................................................................................៧១
៤. សត្វល្អិតខាំ .......................................................................................................៧១
៥. ស្បែកក្រហមដោយកំដៅថ្ងៃ....................................................................................៧២
៦. ជំងឺប៉េស្ដ ..........................................................................................................៧២
៧. ជំងឺត្រចៀកខៀវ .................................................................................................៧៣
៨. ជំងឺក្អក ............................................................................................................៧៣
៩. ជំងឺផ្ដាសាយ .......................................................................................................៧៤
១០. ជំងឺរលាកសួត ..................................................................................................៧៤
១១. ជំងឺអាក់ទីណូបាក់ស៊ីលូស ...................................................................................៧៤
១២. ជំងឺអូហ្យេស្គី ......................................................................................................៧៥
១៣. ជំងឺរាគ ...........................................................................................................៧៥
១៤. ព្រូនអាស្ការីស ...................................................................................................៧៨
១៥. ក្លូន ឬអ៊ែកនី .....................................................................................................៧៩
១៦. ជំងឺរលាកតម្រងនោម ឬផ្លោកនោម ........................................................................៧៩
១៧. ជំងឺរលាកស្បូន ឬផ្លោកនោម...................................................................................៧៩
១៨. ដំបៅលើប្រដាប់បន្តពូជ .........................................................................................៨០
១៩. ទឹកនោមមានពណ៌ខុសពីធម្មតា ..............................................................................៨០
២០. ដំបៅក្រពះ .......................................................................................................៨០
២១. ការប្រកាច់ .......................................................................................................៨១
២២. ជំងឺតេតាណូស ..................................................................................................៨១
២៣. ជំងឺហើម .........................................................................................................៨១
២៤. ជំងឺរលាកសន្លាក់ ...............................................................................................៨២

២៥. បែកក្រចកជើង ..................................................................................... ៨២
២៦. ជំងឺអុតក្តាម .......................................................................................... ៨៣

**ផ្នែកទី៣ : បច្ចេកទេសចិញ្ចឹមគោថ្នាលក្នុងលក្ខណៈគ្រួសារ**
ជំពូក ១ : របៀបចិញ្ចឹមគោ ............................................................................... ៨៧
១. ជំរក ឬរោងគោ ....................................................................................... ៨៧
២. ស្នូកចំណី និងទឹក ................................................................................... ៨៧
៣. ការជ្រើសរើសពូជ .................................................................................... ៨៧
៤. ប្រព័ន្ធរំលាយអាហារ ................................................................................ ៨៩
៥. តម្រូវការសារធាតុចិញ្ចឹម ........................................................................... ៩០
ជំពូក ២ : ដំណាំចំណីសត្វសម្រាប់គោ ................................................................ ៩៣
១. ពពួកស្មៅ .............................................................................................. ៩៣
២. ពពួកលេហ្គីម ......................................................................................... ៩៣
៣. ឈ្មោះប្រភេទពូជដំណាំចំណីសត្វសំខាន់ៗ ដែលមានដាំនៅកម្ពុជា.................................. ៩៤
៤. ពពួកស្មៅ និងអត្ថប្រយោជន៍......................................................................... ៩៦
៥. ពពួកលេហ្គីម និងអត្ថប្រយោជន៍ .................................................................. ៩៨
៦. ប្រភេទដំណាំផ្សេងៗទៀត និងអត្ថប្រយោជន៍ ..................................................... ៩៨
ជំពូក ៣ : បច្ចេកទេសកែច្នៃចំណីសត្វ ................................................................. ៩៩
១. ការធ្វើផ្អកស្មៅជាចំណីបំប៉នគោ ក្របី ( Silage Making for Ruminant Feed ) ................. ៩៩
២. ការធ្វើចំបើងផ្អាប់ជាចំណីគោ....................................................................... ១០១
៣. ការកែច្នៃស្លឹកដំឡូងមី................................................................................ ១០៣
៤. ការធ្វើចំណីផ្សំតាមផ្ទះកសិករ សម្រាប់ជាចំណីបំប៉នគោ........................................... ១០៥
ជំពូក ៤ : ការការពារ និងការព្យាបាលជម្ងឺគោ ..................................................... ១០៧
១. ការការពារសុខភាពសត្វ ............................................................................. ១០៧
២. ជម្ងឺឆ្លងរាតត្បាត ...................................................................................... ១០៨
៣. ជម្ងឺបង្កដោយបរាសិត និងជម្ងឺផ្សេងៗទៀត...................................................... ១១៣
៤. ជម្ងឺលើផ្លូវដង្ហើម ..................................................................................... ១១៧
៥. ជម្ងឺលើផ្លូវរំលាយអាហារ ............................................................................. ១១៩
៦. បញ្ហា និងជម្ងឺលើប្រដាប់បន្តពូជ ................................................................... ១២៤
៧. ជម្ងឺលាសដោះ ........................................................................................ ១២៩
៨. បញ្ហា និងជម្ងឺលើជើង ............................................................................... ១២៩
៩. បញ្ហាខ្វិន ................................................................................................ ១៣១

# អារម្ភកថា

វិស័យផលិតកម្មសត្វនិងបសុព្យាបាល គឺជាវិស័យមួយយ៉ាងសំខាន់ក្នុងការបង្កើតការងារនិងបង្កើនប្រាក់ចំណូលជូនប្រជាកសិករនៅតាមជនបទ ដែលចូលរួមក្នុងការកាត់បន្ថយភាពក្រីក្រនិងកំណើនជីវភាពគ្រួសារឲ្យមានភាពធូរធារនិងសេដ្ឋកិច្ចរុងរឿង ស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ វិស័យនេះក៏បានចូលរួមចំណែកប្រមាណ១៥% នៃផលិតផលសរុបរបស់វិស័យកសិកម្ម និងប្រមាណ៦% នៃផលិតផលក្នុងស្រុកសរុបនៅឆ្នាំ២០១២ ។

ជារួម វិស័យផលិតកម្មនិងបសុព្យាបាលនៅជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជាជំងឺឆ្លងរាលដាល ចំណីសត្វពុំមានបរិមាណនិងគុណភាពគ្រប់គ្រាន់ ការយល់ដឹងរបស់កសិករលើបច្ចេកទេសនិងការផ្សព្វផ្សាយបច្ចេកទេសនៅមានកម្រិត ថ្លៃដើមផលិតខ្ពស់ និងវិនិយោគទុនលើវិស័យចិញ្ចឹមសត្វនៅមានសន្ទុះយឺត ។ល។

ដើម្បីចូលរួមចំណែកអភិវឌ្ឍវិស័យនេះឲ្យកាន់តែល្អប្រសើរ នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលបានសហការជាមួយអគ្គនាយកដ្ឋានកសិកម្ម ដោយមានការឧបត្ថម្ភថវិកាពីគម្រោងអភិវឌ្ឍកសិកម្មនិងជំរុញកំណើនសេដ្ឋកិច្ច បានរៀបចំចងក្រងសៀវភៅ **“បច្ចេកទេសចិញ្ចឹមមាន់ ជ្រូក និងគោជាលក្ខណៈគ្រួសារ”** ដោយផ្អែកលើឯកសារបច្ចេកទេសជាច្រើននិងបទពិសោធន៍ល្អៗដែលអនុវត្តកន្លងមក ដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល គម្រោងចិញ្ចឹមសត្វកម្ពុជា-សហគមន៍អឺរ៉ុប (EU-SLPP) គម្រោងការអនុវត្តល្អប្រសើរលើប្រព័ន្ធផ្តល់ចំណី សម្រាប់ផលិតកម្មគោឲ្យមានប្រសិទ្ធភាពនៅក្នុងប្រទេសកម្ពុជា (ACIAR) គម្រោងបង្ហាញបច្ចេកវិទ្យាដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប (ADB-TSTD) ។

សៀវភៅនេះ មានគោលបំណងជួយពង្រឹងបន្ថែមនូវចំណេះដឹង ចំណេះធ្វើដល់អ្នកផ្សព្វផ្សាយ និងបងប្អូនកសិករសំដៅជំរុញការបង្កើនផលិតកម្មមាន់ ជ្រូក និងគោនៅកម្ពុជា តាមរយៈការបង្ហាញពីបទដ្ឋានបច្ចេកទេសសំខាន់ៗដោយសរសេរជាពាក្យសាមញ្ញ លើកយកឧទាហរណ៍ជាក់ស្តែងនិងដាក់រូបបង្ហាញ ដើម្បីឲ្យងាយយល់ ងាយចាំ មានចំណាប់អារម្មណ៍ និងងាយស្រួលយកទៅអនុវត្ត ។

អ្នករៀបរៀងមានសង្ឃឹមយ៉ាងមុតមាំថា សៀវភៅ **“បច្ចេកទេសចិញ្ចឹមមាន់ ជ្រូក និងគោជាលក្ខណៈគ្រួសារ”** នេះនឹងផ្តល់នូវគំនិតថ្មីៗនិងគោលការណ៍បច្ចេកទេសជាមូលដ្ឋានសម្រាប់ស្ថាប័នពាក់ព័ន្ធ អ្នកផ្សព្វផ្សាយកសិកម្មនិងកសិករយកទៅអនុវត្តក្នុងទិសដៅលើកកម្ពស់ ផលិតកម្មមាន់ ជ្រូក និងគោ ។

យើងខ្ញុំសូមស្វាគមន៍ទទួលយកនូវរាល់យោបល់កែលម្អបន្ថែមពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធ ។

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៣

**នាយកដ្ឋានផលិតកម្មនិងបសុព្យាបាល**

# ផ្នែកទី ១

# បច្ចេកទេសចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ



# លក្ខណៈល្អប្រសើរនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក

ពូជមាន់ក្នុងស្រុកដែលប្រទះឃើញញឹកញាប់ជាងគេ គឺមាន់គក មាន់សំពៅ មាន់ប្រជល់ មាន់កណ្ដូង មាន់ថៃ មាន់សំឡី មាន់ក្រញាស់ មាន់ខ្មៅ មាន់ស្លួយ ។ល។



មាន់គក



មាន់សំពៅ



មាន់ប្រជល់



មាន់កណ្ដូង



មាន់ថៃ



មាន់សំឡី



មាន់ក្រញាស់



មាន់ខ្មៅ



មាន់ស្លួយ

## គុណសម្បត្តិនៃការចិញ្ចឹមមាន់ពូជក្នុងស្រុក:

- ធន់ទៅនឹងអាកាសធាតុ និងការលំបាកគ្រប់បែបយ៉ាង
- មិនចាំបាច់ផ្តល់នូវចំណីផ្សំ (ក្រុមហ៊ុន) ទាំងស្រុង ដោយអាចផ្សំពីចំណីធម្មជាតិ ដែលអាចរកបាននៅក្នុងភូមិ និងមានតម្លៃថោកសមរម្យ
- ងាយស្រួលក្នុងការថែទាំ
- ផ្តល់ស៊ុត ក្រាបភ្ញាស់ និងបណ្តើរកូនដោយខ្លួនវា
- មិនសូវកើតជម្ងឺ និងទប់ទល់ជាមួយជម្ងឺកាចសាហាវបានមួយចំនួន
- សាច់មាន់ស្រុកមានរសជាតិឆ្ងាញ់ និងពេញនិយម
- តម្រូវការទីផ្សារខ្ពស់ (មាន់សាច់ និងស៊ុត) និងមានតំលៃល្អ





# ជំពូក ១
# ទ្រុងសម្រាប់ចិញ្ចឹមមាន់

ទ្រុងមានសារៈសំខាន់ណាស់ សម្រាប់ការពារមាន់ធំ និងកូនមាន់ ពីការយាយីបំផ្លាញផ្សេងៗ និងអាចទប់ទល់អាកាសធាតុប្រែប្រួល ជាពិសេសកូនមាន់តូចៗ ទ្រុងមាន់ដែលល្អត្រូវមានលក្ខណៈដូចខាងក្រោម ៖

- ទីធ្លាទូលាយ
- មានខ្យល់អាកាសស្រឡះល្អ និងស្ងួត
- ងាយស្រួលក្នុងការបោសសម្អាត និងអនាម័យ
- មានទ្រនំសម្រាប់មាន់ដេក
- មានសំបុកគ្រប់គ្រាន់សម្រាប់មេមាន់ពង និងក្រាបពង

ដើម្បីឱ្យការចិញ្ចឹមមាន់បានរីកចំរើន និងធានាសុវត្ថិភាពនោះ កសិករត្រូវអនុវត្តតាមបច្ចេកទេសសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

## ១. ទំហំទីកន្លែងរស់នៅ

សម្រាប់មេមាន់មួយក្បាល និងកូនមាន់ពី១៥ ទៅ ២០ក្បាល ត្រូវការទំហំផ្ទៃដី ១.៥ម × ១.៥ម ។ ដូច្នេះ បើចិញ្ចឹមមេមាន់ ២០ក្បាល កសិករត្រូវមានផ្ទៃដីប្រហែល ៦០-៨០ម² ហើយដើម្បីឱ្យកូនមាន់មានចំនួនច្រើន និងចិញ្ចឹមបំប៉នរហូតដល់ពេលលក់មានសុខភាពល្អ កសិករត្រូវមានដីប្រមាណ១០០-១២០ម²។

## ២. ទ្រុងសម្រាប់ថែរក្សាកូនមាន់

ដើម្បីឱ្យកូនមាន់អាយុពី ១ ទៅ ៣០ថ្ងៃលូតលាស់ល្អ ត្រូវ ៖

- ធ្វើទ្រុងផុតពីដីកំពស់កន្លះម៉ែត្រ
- បាតទ្រុង និងជញ្ជាំងអាចធ្វើពីបន្ទះឬស្សី ឬក៏សំណាញ់ដែក ឬនីឡុង។
- បាតទ្រុងត្រូវក្រាលអង្កាម ឬកំទេចអាចម៍រណា (ដើម្បីរក្សាកំដៅ) រហូតដល់កូនមាន់មានអាយុ ៣០ថ្ងៃ ទើបលែងដាក់ ។
- ជញ្ជាំងទ្រុង និងពីលើទ្រុងពទ្ធ័ដោយបាវ ឬក្រដាសដើម្បីរក្សាកំដៅ ពិសេសពេលយប់ និងអាកាសធាតុត្រជាក់។

**បញ្ជាក់:**

នៅពេលកូនមាន់អាយុបាន ៣០ថ្ងៃ ត្រូវបញ្ជូនទៅដាក់ក្នុងទ្រុងបំប៉ន រហូតដល់ពេលលក់ ។



*ទ្រុងកូនមាន់ជញ្ជាំងធ្វើពីបន្ទះរនាបឬស្សី*



*ទ្រុងកូនមាន់ជញ្ជាំងធ្វើពីសំណាញ់*



*ដើម្បីរក្សាកំដៅ ត្រូវបាំងជុំវិញទ្រុងកូនមាន់*



សំយ៉ាបរោងសម្រាប់ដាក់ទ្រុងកូនមាន់

## ៣. ទ្រុងសម្រាប់មាន់ធំ

ជាទូទៅការចិញ្ចឹមមាន់មាន ២ របៀបសំខាន់ៗ គឺការចិញ្ចឹមលែង និងចិញ្ចឹមដាក់ទ្រុង ។

**តើត្រូវចិញ្ចឹមមាន់ក្នុងសណ្ឋានទ្រុងទីធ្លាបិទជិតយ៉ាងដូចម្ដេច?**

សណ្ឋានទ្រុងនេះ គឺនៅពេលយប់បញ្ចូលមាន់ឱ្យដេកនៅក្នុងទ្រុង ចំណែកឯពេលថ្ងៃព្រលែងឱ្យដើរស៊ីក្នុងរបងសំណាញ់បិទជិត ។

**គុណសម្បត្តិនៃការចិញ្ចឹមដាក់ទ្រុងគឺ :**

- ងាយស្រួលក្នុងការគ្រប់គ្រង
- ងាយស្រួលក្នុងការផ្ដល់ចំណី និងការថែទាំ
- ងាយស្រួលក្នុងការចាក់ថ្នាំការពារ និងការតាមដានជម្ងឺ និងការធ្វើអនាម័យ
- ការពារការឆ្លងរាលដាលនៃជម្ងឺ ដែលឆ្លងរាតត្បាតពីខាងក្រៅ
- ការពារ និងរារាំងពីការបំផ្លាញដោយសត្វផ្សេងៗ

ប៉ុន្តែទ្រុងរបៀបនេះ ត្រូវការចំណាយដើមទុនច្រើនក្នុងការសាងសង់ និងធ្វើរបងព័ទ្ធជុំវិញ សម្រាប់ឱ្យមាន់ ដើរខាងក្នុង ហើយម្យ៉ាងទៀតត្រូវចំណាយចំណីស្ទើរតែទាំងស្រុងសម្រាប់ផ្ដល់ឱ្យមាន់ស៊ី ។

### ៣.១. ការសាងសង់ទ្រុងមាន់

ទ្រុងមានសារៈសំខាន់ណាស់ សម្រាប់ការពារមាន់ឱ្យចៀសផុតពីកត្តាចង្រៃផ្សេងៗដែលមកយាយី។ ហេតុនេះ ទ្រុងត្រូវសាងសង់ឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ។ ដំបូងកសិករជ្រើសរើសទីកន្លែងដែលមានទីទួល ឬមិនលិចទឹក ហើយចាក់ដីបំពេញឱ្យបានខ្ពស់ជាងផ្ទៃដីធម្មតា ដោយបុកបង្ហាប់ល្អ ដើម្បីជៀសវាងកុំឱ្យទឹកភ្លៀង ហូរកាត់ក្នុងទ្រុង ។ ចំពោះផ្ទៃដីដែលចាក់ នេះត្រូវធំជាងតួររោង ០,៥ ម៉ែត្រ ជុំវិញ ។

- ទំហំរោងមាន់ (ទ្រុងដេកយប់) ៥ម x ១០ម ដែលចែកជាខ័ណ្ឌៗដោយសំណាញ់
- ខាងក្រៅរោងព័ទ្ធសំណាញ់ ជាខ័ណ្ឌៗ កុំឱ្យមាន់ចេញក្រៅ
- តួររោង និង សសរធ្វើពីឈើ
- ជញ្ជាំងទ្រុងធ្វើពីបន្ទះឫស្សី ដែលគម្លាតពីមួយទៅមួយប្រវែង ១ ស.ម
- ទ្រុងមានកម្ពស់ជើងរៀង ១,៧ ម និងសសរកណ្ដាលកម្ពស់ ៣,២ ម
- ដំបូលគួរធ្វើពីស្បូវ ឬ ពីស្លឹកត្នោត
- គ្រោងទ្វារធ្វើពីកូនឈើ ឬ ពីឫស្សី
- ដាក់ទ្រនំដេកកំពស់ពីដី ៧០ ស.ម និងមានបន្ទាធ្នើរ ៧០ ស.ម
- សំបុកសម្រាប់មេមាន់ពង ត្រូវនៅខ្ពស់ជាងទ្រនំដេក
- ត្រូវធ្វើជណ្ដើរសម្រាប់មេមាន់ឡើងក្រាបពង និង មាន់ឡើងដេក




ប្លង់គំរូទ្រុងមាន់ សណ្ឋានទ្រុងទីធ្លាបិទជិត (មើលចំពីលើ)



តួរោងទាំងមូលរបស់ទ្រុងមាន់

នៅជុំវិញទ្រុង ជាការល្អត្រូវដាំដើមកន្ទំថេត ដើមងប់ ត្រកួន ដំឡូងឈើ ដើម្បីផ្តល់ជាអាហារបន្ថែមដ៏ល្អសម្រាប់មាន់។

### ៣.២. ទ្រនំ ឬ ផ្ទើរសម្រាប់មាន់ដេក

- ទ្រនំងាយស្រួលប្រមូលលាមកធ្វើជី និងងាយស្រួលសម្អាត
- ទ្រនំត្រូវទាបជាងសំបុក
- ចន្លោះផ្ទើរបង្កងមានប្រវែង ២០សង់ទីម៉ែត្រ ឬ ២តឹក





ផ្ទើទ្រនំសម្រាប់មាន់ដេកធ្វើពីបន្ទះឬស្សី

### ៣.៣. សំបុកមេមាន់

- ត្រូវរៀបចំសំបុកមុនមេមាន់រកពង
- ចំនួនសំបុកត្រូវឱ្យស្មើគ្នាជាមួយចំនួនមេមាន់
- សំបុកអាចធ្វើពីបង្គីរ ឬស្សី កេស ។ល។
- សំបុកដាក់ ឬ ចងជាប់នឹងទ្រុង នៅកន្លែងមិនសូវមានពន្លឺ
- សំបុកអាចធ្វើពីចំបើងស្ងួត ឬស្លឹកចេក ដាក់ឲ្យក្រាស់ ដើម្បីផ្តល់កំដៅដល់ស៊ុតញាស់ល្អ
- ដើម្បីកំចាត់ស្រមើរក្នុងសំបុកត្រូវដាក់កំទេចថ្នាំជក់ ឬស្លឹកចេក ឬស្លឹកសាវម៉ាវព្រៃ ដាក់នៅពីក្រោមសំបុក។





សំបុកសម្រាប់មាន់ពង

## ៤. ស្នូកចំណី និងស្នូកទឹក

ត្រូវដាក់ស្នូកទឹក និងស្នូកចំណីឱ្យបានគ្រប់គ្រាន់សម្រាប់មាន់ ។ ដើម្បីកាត់បន្ថយការចំណាយទិញ និងការកំពប់បាត់បង់ចំណី កសិករគួរកែច្នៃនូវសំភារៈដែលមានស្រាប់នៅក្នុងភូមិ ឬមានតម្លៃថោកៗ សម្រាប់ធ្វើជា ស្នូកចំណី ។ អ្នកចិញ្ចឹមអាចយកបីដុង ឬកានជ័រមកច្នៃជាស្នូកចំណីដែលបង្ហាញដូចរូបខាងក្រោម ៖



ស្នូកចំណីកូនមាន់ធ្វើពីដបជ័រ



ស្នូកចំណីកូនមាន់ជំទង់ធ្វើពីធុងជ័រ



ស្នូកចំណីកូនមាន់ជំទង់ធ្វើពីប៊ីដុងជ័រ



កំប៉ុងទឹកជ័រសម្រាប់មាន់ផឹក



# ជំពូក ២
# ពូជ និងការបង្កាត់ពូជមាន់

ពូជមាន់ក្នុងស្រុក មានលក្ខណៈសម្បត្តិល្អសមស្របសម្រាប់កសិករចិញ្ចឹម និងពង្រីកផលិតកម្ម ។មាន់ឈ្មោលអាចបង្កាត់ពូជបាន លុះត្រាតែវាមានអាយុ ៦ខែ ចំណែកឯមាន់ញីពេញវ័យ និងចាប់ផ្តើមពងនៅពេលដែលវាមានអាយុ ៤-៥ខែ តែវាអាចបង្កកំណើតបាន លុះត្រាតែវាមានអាយុ ៥-៦ខែ ។ ប្រសិនបើ មេមាន់មានសុខភាពល្អ និងមានចំណីគ្រប់គ្រាន់ វានឹងផ្តល់ស៊ុតរៀងរាល់ពេកព្រឹកព្រលឹម ។

## ១. ការបង្កកំណើត

បន្ទាប់ពីពាក់មេ ស្ពែមរស់នៅក្នុងបំពង់នាំអូវុលបាន ២-៣សប្តាហ៍ ។ ស្ពែមអាចមានលទ្ធភាពបង្កកំណើតពេញលេញបានក្នុងរយៈពេល ៦ថ្ងៃ ។ បន្ទាប់ពីនេះលទ្ធភាពបង្កកំណើតរបស់វាថយចុះ ៖

- បន្ទាប់ពីពាក់រួច នៅថ្ងៃទី ១០ លទ្ធផលបង្កកំណើតបានត្រឹមតែ ៥០%
- បន្ទាប់ពីពាក់រួច នៅថ្ងៃទី ១៩ លទ្ធផលបង្កកំណើតបានត្រឹមតែ ១៥%

ជាទូទៅមេមាន់ពងក្នុងមួយលើកៗបានពី ៨-១៣គ្រាប់ ដោយមួយថ្ងៃពងមួយគ្រាប់ ។



## ២. ការបង្កជាស៊ុត និងការក្រាប

បន្ទាប់ពីផ្នែកអង្គលឿងនៃស៊ុតត្រូវបានបង្កកំណើតរួច មិនយូរប៉ុន្មានវានឹងក្លាយជាស៊ុតពេញលេញ ហើយត្រូវបានបញ្ចេញមកក្រៅ ។ អំប្រីយ៉ុងនឹងលូតលាស់ដោយខ្លួនឯង ដោយមិនត្រូវការជំនួយពីមេ លើកលែងតែការក្រាបផ្តល់កំដៅ ។

- ស៊ុតត្រូវការសំណើម និងសីតុណ្ហភាពសមស្រប ដើម្បីញាស់ (៣៨-៣៩អង្សាសេ)
- មេមាន់ក្រាបលើស៊ុតពី ៨-១៣គ្រាប់
- មេមាន់ប្រើចំពុះបង្វិលស៊ុតជាប្រចាំ ដើម្បីការពារកុំឲ្យអំប្រីយ៉ុងស្អិតជាប់សំបក និងដើម្បីផ្តល់អុកស៊ីសែន
- មាន់ក្រាបក្នុងរយៈពេល ២១ថ្ងៃ

## ៣. ការជ្រើសរើសស៊ុតសម្រាប់ភ្ញាស់

- ស៊ុតដែលត្រូវជ្រើសរើសយកមកភ្ញាស់ ត្រូវតែមានទំហំ រូបរាង និងពណ៌ល្អ
- មេមាន់ចាស់ និងមេមាន់ពងដំបូងតែងតែផ្តល់ស៊ុតដែលមានទំហំតូច ដូច្នេះកូនដែលញាស់មកក៏តូចដែរ
- មិនត្រូវភ្ញាស់ស៊ុតក្រខ្វក់ឡើយ
- មិនត្រូវធ្វើការលាងសំអាតស៊ុតទេ ព្រោះវានឹងបំផ្លាញប្រព័ន្ធការពារពីធម្មជាតិរបស់ស៊ុត ។

## ៤ .ការភ្ញាស់ស៊ុត និងការញាស់

ការភ្ញាស់មានពីររបៀប គឺការភ្ញាស់តាមធម្មជាតិ និងការភ្ញាស់ដោយម៉ាស៊ីន ។

### ការភ្ញាស់តាមធម្មជាតិ

- ទុកស៊ុតនៅស្ងៀមក្នុងសំបុក ដើម្បីទុកឲ្យមេក្រាបពង
- សំបុកត្រូវតែគ្មានស្រមោច ឬចៃ
- នៅពេលមេមាន់ពងអស់ វាចាប់ផ្តើមក្រាប
- ក្នុងកំឡុងពេលក្រាបនេះ មេមាន់តែងតែចាកចេញពីសំបុករយៈពេល ១៥នាទី ដើម្បីរកចំណី ពេលនេះមេមាន់មិនសូវស៊ីច្រើនទេ ដូចនេះមុន

ពេលក្រោយវា ត្រូវតែមានសុខភាពល្អ

- ដំណើរការញាស់មានរយៈពេលពី ៤-១២ម៉ោង (មុនពេលកូនមាន់បំបែកសំបកចេញ)
- កូនមាន់បំបែកសំបកចេញដោយខ្លួនឯង ហើយមានសភាពសើម និងអស់កម្លាំង
- រយៈពេល ២-៣ ម៉ោង ក្រោយពីញាស់ វានឹងដេក ហើយសម្រាក
- ក្រោយពេលរោមស្ងួត កូនមាន់នឹងធ្វើចលនា
- ផ្នែកលឿងនៃស៊ុតដែលមាននៅក្នុងខ្លួនវា នៅជាប់រហូតដល់ ៤៨ម៉ោង



## ការភ្ញាស់ដោយប្រើទូរភ្ញាស់

- មិនចាំបាច់ប្រញាប់យកស៊ុតទៅដាក់ក្នុងទូរភ្ញាស់ឡើយ
- គេអាចរក្សាស៊ុតបានរយៈពេល ៦ថ្ងៃ ដោយដាក់ក្នុងបន្ទប់ត្រជាក់
- ដើម្បីការពាររំហួតទឹកចេញ ត្រូវរក្សាស៊ុតក្នុងថង់ប្លាស្ទិក ឬថង់ធ្វើពីកប្បាសដែលស្អាតល្អ
- រក្សានៅកន្លែងដែលមានសុវត្ថិភាព
- ទូរភ្ញាស់ត្រូវធានាថាមានចរន្តខ្យល់នាំអុកស៊ីសែនចូល និងនាំឧស្ម័នកាបូនិកចេញ ព្រមទាំងនាំសំណើម
- រក្សាសីតុណ្ហភាពឲ្យនៅថេរ ក្នុងរង្វង់ ៣៧.៥ អង្សាសេ
- ត្រួតពិនិត្យសំណើម ដោយថ្លឹងស៊ុតមុនដាក់ក្នុងទូរភ្ញាស់ និងនៅពេលភ្ញាស់បាន ១៨ថ្ងៃ (ប្រសិនបើបាត់បង់សំណើមលើស ២០% បានន័យថាខ្យល់ស្ងួតខ្លាំង តែបើបាត់បង់តិចជាង ១០% គឺខ្យល់មានសំណើមខ្ពស់)



*ទូរភ្ញាស់អគ្គីសនី*

## ការបង្វិល

ការបង្វិលស៊ុត ជាគោលបំណងដ៏សំខាន់ដើម្បីឲ្យស៊ុតលឿង នៅចំកណ្ដាលស៊ុត ។ ប្រសិនបើគ្មានការបង្វិលទេអំប្រ៊ីយ៉ុងដំបូងនឹងងាប់ដូចនេះលទ្ធផលញាស់ទាប ។

ចំពោះការភ្ញាស់ដោយធម្មជាតិ មេមាន់តែងប្រើ



*ក្នុងកំឡុងពេលបីថ្ងៃចុងក្រោយ អំប្រ៊ីយ៉ុងនឹងបង្វិលទៅរកទីតាំងញាស់*

ចំពុះ ដើម្បីបង្វិលស៊ុត ។ ប៉ុន្តែចំពោះការភ្ញាស់ដោយទូរភ្ញាស់វិញ ត្រូវបង្វិលស៊ុតឲ្យបាន ៤ដងក្នុងមួយថ្ងៃ ។ ក្រោយពេលដាក់ភ្ញាស់បាន ១៨ថ្ងៃ មិនចាំបាច់បង្វិលស៊ុតទៀតទេ ជាពិសេស ៣ថ្ងៃចុងក្រោយនៃការភ្ញាស់ មិនត្រូវបង្វិលស៊ុតឡើយ ។

ក្នុងកំឡុងពេលបីថ្ងៃចុងក្រោយ អំប្រីយ៉ុងនឹងបង្វិលទៅរកទីតាំងញាស់

### ការឆ្លុះស៊ុត

បន្ទាប់ពីភ្ញាស់បាន ១សប្តាហ៍ តាមរយៈការឆ្លុះ យើងអាចឃើញបណ្តាញសរសៃឈាមព័ទ្ធជុំវិញចំណុចខ្មៅ នោះមានន័យថាអំប្រីយ៉ុងលូតលាស់ល្អ ។

ការឆ្លុះនេះមានសារៈសំខាន់ណាស់សម្រាប់ឲ្យយើងយកស៊ុតដែលខូចចេញ ចៀសវាងក្លិនស្អុយ នៅក្នុងទូរភ្ញាស់ ។

ដើម្បីឆ្លុះស៊ុតបាន ត្រូវដាក់ពន្លឺក្នុងប្រអប់មួយដែលមានចោះប្រហោងប៉ុនទំហំស៊ុត ។



*ការឆ្លុះស៊ុត*

ក្នុងកំឡុងពេលបីថ្ងៃចុងក្រោយ អំប្រីយ៉ុងនឹងបង្វិលទៅរកទីតាំងញាស់

## ៥ ការជ្រើសរើសកូនមាន់ចិញ្ចឹម

- រាងល្អ ភ្លៀវភ្លា ជើងលឿង
- ចំពោះកូនមាន់ដែលរោមស្អិតជាប់គ្នា ហើយពោះធ្លាក់ ឬរឹង និងមានព័ណខៀវមិនគួរយកមកចិញ្ចឹមទេ។



*កូនមាន់មានសភាពរស់រវើក និងភ្លៀវភ្លា*

## ៦ ការជ្រើសរើសបាមាន់

- រាងល្អ ភ្លៀវភ្លា ជើងលឿង
- មាឌធំ ទម្ងន់ ២,៥ គីឡូក្រាម
- ពូកែជាន់មេ (បង្កាត់ពូជ)
- មានអាយុចាប់ពី ៩ ខែ ឡើង តែមិនត្រូវលើសពី ៣ ឆ្នាំឡើយ
- មានមេបាដែលមានកូនច្រើន និងគ្មានជម្ងឺឆ្លង



*បាមាន់មាឌធំ និងសុខភាពល្អ*

## ៧ ការជ្រើសរើសមេមាន់

- រាងល្អ ខ្លាំងមាំ ជើងលឿង
- គ្មានជំងឺ និងសុខភាពល្អ
- ត្រូវមានអាយុ ៧ ខែឡើង និងមានទម្ងន់ច្រើនជាង ១,២ គីឡូក្រាម
- រើសចេញពីមេមាន់ដែលបានផ្តល់កូន ៤ សារក្នុងមួយឆ្នាំយ៉ាងតិច
- ពងមួយសារពី ១០ ទៅ ១២ ពង ហើយអត្រាញាស់ ពី ៨ ក្បាលឡើង ហើយដែលកូនមាន់ទាំងនោះសកម្ម និងក្លៀវក្លា។




*ពូជមេមាន់មានមាឌធំ និងជើងសម្បុរលឿង*

**សំគាល់:**

មេ និងបា គួរមានស្រការជើងក្រាស់ល្អ ជើងមាំ សិរក្រហម ស្បែកកស្តើងទន់ ។ បា១ក្បាល សម្រាប់មេ ៦ ទៅ ៧ ក្បាល។

## ៨. ការបង្កាត់ពូជមាន់

យើងអាចជ្រើសរើសពូជមាន់មកចិញ្ចឹម អាស្រ័យលើគោលបំណងរបស់អ្នកចិញ្ចឹម ។ ពូជមាន់ក្នុងស្រុកមានលក្ខណៈសមស្របបំផុតសម្រាប់ស្ថានភាពកសិករក្នុងពេលបច្ចុប្បន្ននេះ ។ បើអ្នកចិញ្ចឹម ចង់បានផលិតកម្មសាច់ខ្ពស់ និងលូតលាស់លឿន ត្រូវយកពូជមាន់មេក្នុងស្រុកបង្កាត់ជាមួយពូជកូនកាត់នាំចូល ដូចជា៖ ពូជកូនកាត់អ៊ីសាប្រោន (ខេអាយ) ជាដើម ។ ប៉ុន្តែត្រូវជ្រើសរើសប្រភេទពូជនាំចូលដែលមានសម្បុរប្រហាក់ប្រហែលពូជក្នុងស្រុក ទើបងាយស្រួលលក់ និងមានតម្រូវការសម្រាប់ទីផ្សារខ្ពស់ ។

### ពូជក្នុងស្រុក

- ស៊ាំទៅនឹងមជ្ឈដ្ឋានបានខ្ពស់
- សមស្របទៅនឹងអ្នកចិញ្ចឹមតូចតាច ព្រោះវាអាចដើរកកាយរកស៊ីដោយខ្លួនឯង និងងាយស្រួលចិញ្ចឹម
- វាមានដងខ្លួនតូច ដូចនេះវាត្រូវការចំណីតិចដែរ
- ពេញវ័យនៅអាយុ ២៨សប្តាហ៍
- ផ្តល់ស៊ុតតិច (៤០-៦០ គ្រាប់ក្នុងមួយឆ្នាំ) និង
- ស៊ុតមានទម្ងន់ពី ២៥-៤៥ក្រាម ក្នុងមួយគ្រាប់



- ចំនួនកូនមាន់ញាស់ក្នុងមួយសំបុកទាប (មួយសម្បុកជាមធ្យម ៧ក្បាល)
- វដ្តផលិតកម្មវែង (ពង ១៦ថ្ងៃ ក្រាប ២១ថ្ងៃ បណ្តើរកូន ៤២ថ្ងៃ)
- មេមាន់ភាគច្រើនផលិតកូនបានពី ៤-៥ដងក្នុងមួយឆ្នាំ
- បញ្ហាកង្វះចំណី ជម្ងឺ ពពួកសត្វចង្រៃ និងគ្រោះថ្នាក់ផ្សេងៗ ធ្វើឲ្យអត្រាស្លាប់មានដល់ពី ៦០-៧០%
- ស៊ុតភាគច្រើន ទុកសម្រាប់ភ្ញាស់ មិនមែនសម្រាប់លក់ ឬសម្រាប់ហូបទេ
- អាយុលើសពី ៦ខែ មានទម្ងន់ត្រឹមតែ ១.២-១.៥គ្រ
- បរិមាណសាច់ទាប តែមានរសជាតិ



មេមាន់ពូជក្នុងស្រុកបណ្តើរកូន ៩ក្បាល



មេមាន់បណ្តើកូនលើស ១ខែ ទោះកូននៅតែបីក្បាល





# វដ្តផលិតកម្មមាន់ និងការថែរក្សាកូនមាន់

## ១. វដ្តផលិតកម្មមាន់

វដ្តផលិតកម្ម ឬ រយៈពេលញាស់មួយសំបុករបស់មេមាន់ ១ក្បាល មានរយៈពេល ៥៦ថ្ងៃ ប្រសិនបើអ្នកចិញ្ចឹមអនុវត្តតាមបច្ចេកទេសបង្ហាញខាងក្រោម។ ដូច្នេះមេមាន់ ១ក្បាល អាចទទួលបានកូនមាន់ជាមធ្យម ៥-៧ សំបុក ក្នុង ១ឆ្នាំ។




គំនូសតាងវដ្តផលិតកម្មកូនមាន់

### សំគាល់:

បើសិនជាកសិករមានបទពិសោធន៍គ្រប់គ្រាន់ នោះកសិករអាចបំបែកកូនចេញពីមេ បន្ទាប់ពីញាស់រួចភ្លាម ដូច្នេះក្នុង ១ឆ្នាំ កសិករអាចទទួលបានកូនមាន់ពី ៧-៨សំបុក សម្រាប់មេមួយក្បាល ។ ប៉ុន្តែកូនមាន់ទាំងនោះត្រូវការថែរក្សាយ៉ាងត្រឹមត្រូវ ។

## ២. ការថែរក្សាកូនមាន់ទើបញាស់

កូនមាន់ដែលទើបញាស់ងាយរងគ្រោះ និងអត្រាស្លាប់ខ្ពស់ប្រសិនបើមិនបានថែរក្សាត្រឹមត្រូវ ។ ដូច្នេះ ដើម្បីការពារកូនមាន់កុំឱ្យស្លាប់ ត្រូវអនុវត្តដូចខាងក្រោមៈ

- ថែរក្សានៅកន្លែងដែលមានសុវត្ថិភាព
- កម្រាលត្រូវតែស្ងួត (អាចប្រើចំបើង ឬអង្កាម) ដើម្បីងាយស្រួលក្នុងការប្រមូលជាប្រចាំ
- ដាក់កូនមាន់ ២០ក្បាល ក្នុង ១ម$^{២}$
- កន្លែងដែលមានបរិយាកាសក្ដៅល្មម និងស្អាតល្អ

- ផ្ដល់នូវទឹក និងចំណីអាហារដែលងាយស្រួលរំលាយ និងគ្រាប់ល្អិតៗឱ្យបានគ្រប់គ្រាន់។

**តើត្រូវបំបែកកូនមាន់ ចេញពីមេនៅអាយុ ១០ថ្ងៃ ដូចម្ដេច ?**

ក. រៀបចំទ្រុងសម្រាប់ដាក់កូនមាន់រួចជាស្រេច ដោយបាតទ្រុងដាក់អង្កាម ឬកំទេចអាចម៍រណារ

ខ. ត្រូវយកទាំងមេ និងកូន ទៅដាក់ក្នុងទ្រុងកូនមាន់ជាមួយគ្នា ក្រោយពីកូនញាស់អស់

គ. ពេលកូនមាន់អាយុបាន ១០ថ្ងៃ ត្រូវដកមេចេញពីកូនទៅដាក់ក្នុងទ្រុងមេពង ។ មិនអនុញ្ញាតឱ្យមេមាន់ចូលក្នុងទ្រុង ឬមកក្បែរកូនមាន់ឡើយ ។

ឃ. ត្រូវយកបាវ ឬក្រដាសព័ទ្ធជុំវិញទ្រុងកូនមាន់ដើម្បីរក្សាកំដៅ ។

បើសិនត្រជាក់ខ្លាំង ឬ ពេលយប់ ត្រូវបន្ថែមកំដៅដោយប្រើក្អមធ្យូងកំដៅ ឬអំពូលភ្លើង(មូល) ៧០វ៉ាត់ ។

ង. កូនមាន់អាយុបាន ១ខែ ត្រូវយកទៅចិញ្ចឹមនៅក្នុងទ្រុងបំប៉នរហូតដល់ពេលលក់។

**តើត្រូវផ្ដល់កំដៅកូនមាន់ដូចម្ដេច ដើម្បីឱ្យលូតលាស់ល្អ ?**

ការក្រុងរបស់មេៈ បើសិនមេមាន់ វាក្រុងកូនរបស់វាក្រោមស្លាប នោះកូនមាន់ នឹងទទួលកំដៅពីមេវា ៣៥-៣៧ អង្សាសេ។

ការចិញ្ចឹមគ្មានមេៈ ត្រូវផ្ដល់កំដៅឱ្យកូនមាន់ដូចមេមាន់ដែរ

- បើសីតុណ្ហភាពទាប នោះកូនមាន់នឹងខ្សោយ រងា ឈឺ ហើយបណ្ដាលឱ្យការលូតលាស់យឺត
- បើសីតុណ្ហភាពខ្ពស់នឹងធ្វើឱ្យរោមកូនមាន់ដុះមិនល្អ
- ត្រូវត្រៀមកំដៅសម្រាប់កូនមាន់
- ត្រូវផ្ដល់ទឹក និងចំណីឱ្យបានគ្រប់គ្រាន់ និងមានគុណភាព



*ផ្ដល់កំដៅកូនមាន់ដោយប្រើរងើកធ្យូង*



*ផ្ដល់កំដៅកូនមាន់ដោយប្រើអំពូលភ្លើងមូល*

សញ្ញាបង្ហាញពីកំដៅក្នុងទ្រុងកូនមាន់

- កំដៅល្មមគ្រប់គ្រាន់ៈ កូនមាន់ដើររកស៊ីរាយប៉ាយល្អពេញក្នុងទ្រុង
- កំដៅខ្លាំងជ្រុលៈ កូនមាន់ឃ្លាតឆ្ងាយពីប្រភពកំដៅ ឬ ស្រែកយំពេញទ្រុង ឬ រត់ប្រសេចប្រសាច
- កំដៅត្រជាក់ខ្លាំងៈ កូនមាន់ប្រមូលផ្ដុំគ្នា ឬ គរលើគ្នា




សញ្ញាសំខាន់ៗស្តីពីការផ្តល់កំដៅកូនមាន់







# ជំពូក ៤
# ការកែលម្អពូជ និងការជម្រុះមាន់

គោលបំណងសំខាន់ គឺដើម្បីបង្កើនផលិតកម្មសាច់ និងផលិតកម្មស៊ុតខ្ពស់ ។ វិធីសាស្ត្រល្អបំផុតក្នុងការកែលម្អពូជមាន់ គឺការបង្កាត់ខ្វែងរវាងពូជមាន់ក្នុងស្រុកជាមួយពូជនាំចូល ។



មាន់គកពូជកូនកាត់ (មេអ៊ីសាប្រោន ជាមួយបាមាន់ជល់)



កូនមាន់ពូជកូនកាត់

## ១. ការបង្កាត់ពូជ

ការជ្រើសរើសពូជ ដោយប្រើបាពូជកូនកាត់មេអ៊ីសាប្រោន ជាមួយបាមាន់ជល់ មកបង្កាត់ជាមួយមេមាន់ស្រុកផ្តល់នូវ ៖

- បង្កើនការលូតលាស់ដើម្បីឆាប់បានលក់(ខែ)
- បង្កើនគុណភាពសាច់
- រក្សារសជាតិឆ្ងាញ់ដូចមាន់ពូជក្នុងស្រុក
- អាចចិញ្ចឹមក្នុងលក្ខណៈលែងសេរី



បាថ្មីចិញ្ចឹមលែងដូចមាន់ពូជក្នុងស្រុក

## ២. ការជម្រុះ

តាមធម្មតាកសិករមិនដែលជំរុះមាន់ទេ លើកលែងតែវាស្លាប់ ឬឈឺដោយសារជម្ងឺ ។ ការទុកមេ បាមាន់ ចិញ្ចឹមរហូតដល់អាយុច្រើនជាង ៣ឆ្នាំ វាមិនអាចផ្តល់លទ្ធផលល្អទេ ព្រោះវាអាចធ្វើឱ្យមេមាន់ផ្តល់ពងតិច និង អត្រានៃការញាស់តិចដែរ ជាពិសេសអត្រាស្លាប់ខ្ពស់ ។ដូច្នេះដើម្បីឱ្យទទួលបាននូវលទ្ធផលល្អ ត្រូវជំរុះមេមាន់ និងបាមិនឱ្យអាយុលើសពីអាយុ ៣ឆ្នាំ ។ បើសិនជាទុកមេ ត្រូវផ្លាស់ប្តូរបាចេញ ដោយទិញបាថ្មីមកជំនួសវិញ តែត្រូវប្រយ័ត្នការជាន់ឈាមចំពោះបាថ្មី និងប្រយត្ន័ចំពោះការផ្ទុកនូវជម្ងឺឆ្លង ។

# ជំពូក ៥
# ចំណីអាហារសម្រាប់មាន់

## ១. ការផ្តល់ចំណី

ការផ្តល់ចំណីវាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការចិញ្ចឹម ៖

### ការចិញ្ចឹមព្រលែងសេរី

មាន់ដើររកស៊ីចំណីដោយខ្លួនឯង ហើយនៅពេលយប់ដេកលើចុងឈើ ។ នៅពេលថ្ងៃមាន់ដើររកស៊ីចំណីជុំវិញភូមិ ។ ចំណីដែលមាន់ដើររកស៊ីខ្លួនឯងរួមមាន ខ្យង កណ្តៀរ ដង្កូវ ជន្លេន សត្វល្អិត ស្មៅ ស្លឹករុក្ខជាតិ រុក្ខជាតិទឹក អនុផលក្រោយពេលប្រមូលផល ។ ប៉ុន្តែការរកស៊ីចំណីដោយខ្លួនឯងមាន់មិនអាចស៊ីបានគ្រប់គ្រាន់ឡើយ ដូច្នេះត្រូវផ្តល់ចំណីបន្ថែមដល់មាន់ទាំងនោះ ដូចជាកាកសំណល់ផ្ទះបាយ និងអនុផលកសិកម្ម ។



*ការផ្តល់ដើមចេកហាន់ជាចំណីបន្ថែមដល់មាន់*

### ការចិញ្ចឹមដោយមានផ្ទា

មាន់ដើររកស៊ីចំណីដោយខ្លួនឯង ហើយនៅពេលយប់គេឲ្យដេកក្នុងទ្រុង ។

### ការចិញ្ចឹមពាក់កណ្តាលវប្បកម្ម

មាន់ដើររកស៊ីចំណីដោយខ្លួនឯងក្នុងកន្លែងកំណត់មួយ និងផ្តល់ចំណីបន្ថែមដល់មាន់ទាំងនោះ ដូចជា កាកសំណល់ផ្ទះបាយ និងអនុផលកសិកម្ម ។

ការចិញ្ចឹមមាន់ដាក់ទ្រុងបង្ខាំង គឺមាន់ពឹងផ្អែកទាំងស្រុងទៅលើការផ្តល់ចំណីឱ្យ ។ តម្រូវការចំណីនេះមានការកើនឡើងទៅតាមអាយុ និងទម្ងន់របស់វា ។ មាន់ត្រូវការចំណីដែលមានគុណភាពសម្រាប់ទ្រទ្រង់រាងកាយ ការរីកលូតលាស់ ផលិតកម្មស៊ុត និងសាច់។ កូនមាន់តូចៗដែលមានអាយុពី ១ ថ្ងៃ ដល់ ៤៥ ថ្ងៃ ត្រូវការចំណីដែលមានគុណភាពល្អ និងមានគុណភាពខ្ពស់ដើម្បីការលូតលាស់របស់វា ។

ការផ្តល់ចំណីបន្ថែម មានសារៈសំខាន់ណាស់ ព្រោះវាជួយរក្សាមាន់នៅរដូវខ្សត់ចំណី (រដូវប្រាំង)ជួយផ្តល់បន្ថែមនូវប្រភពវីតាមីន រ៉ែ ប្រូតេអ៊ីន និងថាមពលដែលខ្វះនៅក្នុងចំណីពេលវារកស៊ីដោយខ្លួនឯង ដើម្បីឲ្យមាន់មាន៖

- សុខភាពល្អ
- ការលូតលាស់ធំធាត់លឿន
- ការបន្តពូជល្អ

ក្រៅពីចំណី ត្រូវផ្តល់ទឹក ដល់មាន់ឱ្យបានគ្រប់គ្រាន់ជាប្រចាំ ។

## ២. វត្ថុធាតុដើមសម្រាប់ផ្សំចំណី

### ២.១ ស្រូវ និងអនុផល

ជាចំណីដែលគេប្រើសម្រាប់ផ្តល់ជាចំណីបន្ថែមដោយផ្តល់នូវ ៖



- ចុងអង្គរ ជាចំណីផ្តល់នូវថាមពល
- កន្ទក់ ជាចំណីផ្តល់នូវថាមពល និងមានប្រូតេអ៊ីនពី ៨-១២% ហើយសំបូរផូស្វ័រ និង វីតាមីន បេ ។

## ២.២ ពោត

កសិករកម្រប្រើណាស់ តែពោតជាប្រភេទចំណីមាន់ដែលមានប្រសិទ្ធិភាពខ្ពស់ ដែលកសិករគួរតែកិនធ្វើជាចំណីសម្រាប់មាន់ ព្រោះវា

- ជាប្រភពផ្តល់នូវថាមពល
- មានប្រូតេអ៊ីនពី ៩-១០%
- ជាអ្នកផ្តល់ពណ៌( ជួយបង្កើនពណ៌លឿងនៅស្បែក និងស៊ុត )



## ២.៣ សណ្តែកសៀង

គេកម្រផ្តល់ឲ្យមាន់ចិញ្ចឹមព្រលែងសេរីណាស់។ សណ្តែកសៀងមានសារៈសំខាន់បំផុតសម្រាប់ផ្សំជាចំណី ប៉ុន្តែគេចាំបាច់ត្រូវតែចំអិនជាមុន ដោយលីង ឬស្ងោរក្នុងរយៈពេលពី ២០-៣០នាទី ។ វាផ្តល់នូវ

- ប្រភពផ្តល់ថាមពល ( សំបូរជាតិប្រេង )
- មានប្រូតេអ៊ីនលើសពី ៤០%



## ២.៤ មើមដំឡូងមី

មើមដំឡូងមីមានថាមពលខ្ពស់ តែវាខ្សត់ ប្រូតេអ៊ីន ។ ប៉ុន្តែមើមដំឡូងមីមានជាតិល្វីង ដូចនេះដើម្បីឲ្យមាន់ស៊ីបានច្រើន ចាំបាច់ត្រូវតែលាយជាមួយវត្ថុធាតុដើមផ្សេងៗទៀត ។

គ្រប់ផ្នែកទាំងអស់របស់ដំឡូងមី មុននឹងប្រើប្រាស់ជាចំណីសត្វ ត្រូវហាលឲ្យស្ងួតដើម្បីកាត់ជាតិពុល ។



## ២.៥ ស្លឹកដំឡូងមី

មុននឹងប្រើចាំបាច់ត្រូវហាលជាមុន ។

- វាសំបូរប្រូតេអ៊ីន (មានលើសពី ២០%)
- សំបូរវីតាមីន និងសំបូរសារធាតុផ្តល់ពណ៌ដែលជួយបង្កើនពណ៌លឿងដល់ស្បែក និងស៊ុត
- ជួយបង្កើនភាពស៊ាំ ដែលជួយទៅលើសុខភាព
- សម្រាប់មាន់ពង គេប្រើ ១០ក្រាម ក្នុងមួយក្បាល ក្នុងមួយថ្ងៃ ។



# ៣. សមាសធាតុចំណីសំបូរជាតិសាច់(ប្រូតេអ៊ីន)

ប្រូតេអ៊ីនមានសារៈសំខាន់សម្រាប់ជួយការលូត

លាស់របស់រាងកាយ សាច់ ស្បែក សម្រាប់ផលិតពង។ ប្រូតេអ៊ីន អាចរកបានពី កន្ទក់ ចុងអង្ករ ត្រី ម្សៅត្រី ម្សៅត្រីក្រៀម កង្កែប ជន្លេន កូនដង្កូវ សត្វល្អិត ពពួកសណ្តែក សាច់ដូងស្ងួត ស្លឹកកន្ធំថេត ស្លឹកដំឡូងឈើស្ងួត ត្រកួន ចកបាយទា ។ល។

ចំពោះប្រភេទរុក្ខជាតិបន្លែត្រូវហាលឱ្យស្ងួតល្អ និង បុកឱ្យម៉ត់មុនឱ្យមាន់ស៊ី ។ ចំណែកឯការកែច្នៃស្លឹកដំឡូងឈើស្ងួតជាប្រភពប្រូតេអ៊ីនអាចអនុវត្តដូចតទៅ៖

- យកតែស្លឹកដំឡូងមីផ្នែកខាងចុងប្រហែល ៣ ទៅ ៤ តឹក
- កាប់ចិញ្ច្រាំស្លឹកដំឡូងមីឱ្យតូចល្អិត ហើយហាលឱ្យស្ងួតល្អ
- បន្ទាប់មកយកស្លឹកដែលស្ងួតបុកឱ្យម៉ត់ជាម្សៅ
- លាយម្សៅស្លឹកដំឡូងមីស្ងួត ជាមួយសារធាតុផ្សំចំណីផ្សេងៗទៀតដែលកសិករមាន។


ជន្លេន


កំពិស


កូនត្រី


សាច់ខ្យង


កណ្តូប


ចង្រិត


មេភ្លៀង


កណ្តៀរ


ដង្កូវ


សណ្តែកបាយ


សណ្តែកសៀង


ស្លឹកដំឡូងមី


ស្លឹកកន្ធំថេត

ប្រភពចំណីផ្តល់នូវប្រូតេអ៊ីន

## ៤. សមាសធាតុចំណីសំបូរថាមពល

ជាសារធាតុមួយ ជួយផ្តល់ថាមពលក្នុងការរស់នៅ ផលិត ឬស៊ីចំណី និងការធ្វើចលនា ។ ប្រភពថាមពល អាចមាននៅក្នុងពោត ចុងអង្ករ កន្ទក់ កាកដូងស្ងួត មើមរុក្ខជាតិ កាកសំណល់បន្លែ ដំឡូងជ្វា កាកសំណល់ផ្លែឈើ ពពុះស្ករត្នោត ស្ករ កាកសំណល់ប្រេង-ខ្លាញ់។

ប្រភពចំណីអាហារផ្តល់ថាមពល


ស្រូវ និងអង្ករ


ពោត


ដំឡូងជ្វា


កន្ទក់

ចំពោះមើមដំឡូងមី និងត្រាវ គេអាចកាត់ហាលថ្ងៃ បន្ទាប់មកបុក ឬ កិនឱ្យម៉ត់សម្រាប់ចំណីមាន់។

**ចូរប្រយ័ត្ន !**

ចិតយកសំបកមើមដំឡូងចេញ ពីព្រោះវាមានជាតិពុល។

## ៥. សមាសធាតុចំណីសំបូរជីវជាតិរ៉ែ

សារធាតុរ៉ែជាពិសេស កាល់ស្យូម និងផូស្វ័រ មានសារៈសំខាន់ធ្វើឱ្យឆ្អឹងលូតលាស់ល្អ និងបង្កើតសំបកស៊ុត។ កង្វះកាល់ស្យូម និងផូស្វ័រ បណ្តាលឱ្យមាន់លូតលាស់យឺត មេមាន់រាគពង (ពងចេញមកមានសំបកទន់ៗ) និង ចឹកស៊ីពង ឬ សំបកពងខ្លួនឯង។ ប្រភពនៃជីវជាតិរ៉ែមាន៖ សំបកខ្ចងខ្ចៅ សំបកក្តាម ឆ្អឹងត្រី អំបិល ថ្លើមសត្វ។



របៀបផលិតម្សៅកាល់ស្យូម

## ៦. សមាសធាតុចំណីសំបូរវីតាមីន

ចំណីដែលសំបូរទៅដោយវីតាមីនមានៈរុក្ខជាតិបៃតង ស្លឹកបាស កន្ទំថេត ស្មៅ ត្រកួន ចក ។ល។




រុក្ខជាតិសំបូរវីតាមីន

**បំរាម:**

មិនត្រូវឲ្យមាន់ស៊ីបន្លែ ឬរុក្ខជាតិបៃតងដែលបាញ់ថ្នាំពុលឡើយ ព្រោះវាអាចបណ្តាលឲ្យមាន់មាន សុខភាពមិនល្អ (ឈឺ) និងស្លាប់ ជាពិសេសកូនមាន់ ។

## របៀបធ្វើថ្នាលស្មៅ និងបន្លែជាចំណីមាន់

កសិករគួរតែធ្វើថ្នាលដាំស្មៅច្រើនប្រភេទ លាយជាមួយត្រកួននៅជិតផ្ទះ ឬជិតទ្រុងមាន់ ដើម្បីងាយស្រួលផ្គត់ផ្គង់ចំណីមាន់ ដែលជួយកាត់បន្ថយការចំណាយលុយទិញ ឬ ចំណាយពេលវេលាច្រើនសម្រាប់ដើររក។មុនផ្តល់ឱ្យមាន់ស៊ីត្រូវហាន់វាឱ្យល្អិតៗជាមុនរួចយកទៅច្របល់លាយជាមួយចំណីផ្សំផ្សេងៗទៀត។



ថ្នាលដាំស្មៅលាយជាមួយត្រកួន



ហាន់ស្មៅ និងត្រកួនឲ្យល្អិតៗលាយជាមួយចំណី

## ៧. ការចិញ្ចឹមជន្លេនក្រហម សម្រាប់ជាចំណីបំប៉ន

៧.១ សារៈប្រយោជន៍របស់ជន្លេនក្រហម

- ងាយស្រួលចិញ្ចឹម
- ជន្លេនសំបូរដោយប្រូតេអ៊ីន
- ផ្តល់ជាចំណីជាតិសាច់ (ប្រូតេអ៊ីន) សម្រាប់ឱ្យមាន់លូតលាស់ល្អ
- ជួយកាត់បន្ថយការចំណាយលើចំណីសម្រាប់ចិញ្ចឹមមាន់



*ពូជជន្លេនក្រហម*

## ៧.២ របៀបចិញ្ចឹមជន្លេន ដើម្បីឲ្យលូតលាស់បានល្អ

**ក-ទីកន្លែងសមស្របសម្រាប់ចិញ្ចឹមជន្លេន**

- មានទីទួលមិនលិចទឹក ឬទឹកហូរកាត់
- មានផ្ទៃដីបាតរាបស្មើ
- មិនមានសំបុកស្រមោចនៅក្បែរ
- ធានាសុវត្ថិភាពពីការបំផ្លាញពីកត្តាផ្សេងៗ

**ខ-របៀបរៀបចំការចិញ្ចឹម**

ដើម្បីឱ្យបានជោគជ័យ ត្រូវអនុវត្តដូចខាងក្រោម៖

- ដាក់របាព័ទ្ធជុំវិញ ២ ជាន់ផុតពីដី ដែលមានទទឹង១,២ម បណ្តោយ ២,៥ម ទៅ ៣ម និងកំពស់ ០,៣ម (៣តឹក)។
- របាខាងក្រោមមានកំពស់ពីដី ០,១៥ម និងរបាខាងលើមានកំពស់ពីដី ០,៣ម
- ជញ្ជាំង និងបាតក្រាលដោយផ្ទាំងកៅស៊ូក្រាស់ រួចចោះរន្ធតូចៗនៅបាតដើម្បីកុំឲ្យជាំទឹក
- ដាក់លាមកគោស្រស់កំរាស់ ០,១ ម
- ស្រោចទឹកឱ្យសើម ទើបដាក់ពូជជន្លេន បន្ទាប់មកអាចស្រោចទឹកពីលើបន្តិចទៀត
- ធ្វើដំបូលការពារកំដៅ និងភ្លៀងឱ្យបានជិតល្អ
- ធ្វើគម្របពីលើដើម្បីការពារពីការស៊ីបំផ្លាញពីសត្វផ្សេងៗ (សត្វគីង្គក់ ហ៊ីង កង្កែប ថ្លែន ស្រមោច...)



*រៀបចំកន្លែងចិញ្ចឹម និងដាក់លាមកគោ*



*ស្រោចទឹកឱ្យសើមល្មម*



ដាក់ពូជជន្លេនចិញ្ចឹម



ការធ្វើជំបូលការពារកំដៅ និង ភ្លៀង

**គ-របៀបថែទាំ និងផ្ដល់ចំណី**

- ស្រោចទឹក ២ថ្ងៃម្ដងការពារកុំឱ្យស្ងួត
- បន្ថែមចំណីដោយលាមកគោ ៣ ថ្ងៃ ម្ដង

**ឃ-ការផ្ដល់ចំណី(ជន្លេន)ឱ្យមាន់ស៊ី**

- រយៈពេល ២ ខែអាចប្រមូលផលជន្លេន ឲ្យមាន់ស៊ីបាន



ការដាក់ជន្លេនឲ្យមាន់ជាចំណីបន្ថែម

- ក្នុង ១ថ្ងៃ អាចផ្ដល់ជន្លេនឱ្យមាន់មួយ ក្បាល ស៊ីចំនួនពី ៣-៤ជន្លេន

## ៨. ការផលិតកូនដង្កូវ

ដើម្បីផលិតបានជាកូនដង្កូវត្រូវ ៖

- យកកាកសំណល់ផ្ទះបាយ និងបន្លែ ដាក់ចូលក្នុងធុង ដើម្បីឲ្យរុយពងដាក់
- ដើម្បីឲ្យបានកូនដង្កូវច្រើន អាចបន្ថែមលាមកមាន់ទៅក្នុងធុងនោះ
- នៅពេលក្ដៅខ្លាំង ត្រូវគ្របធុងនោះ ដើម្បីចៀសវាងកុំឲ្យពងរុយងាប់
- កូនដង្កូវអាចត្រូវប្រមូលទៅឲ្យមាន់ស៊ីបាន នៅពេលវាលូតលាស់បានពី ៥-១០ថ្ងៃ ។
- បើលើសពីនេះ កូនដង្កូវនឹងលូតលាស់ ក្លាយជារុយ ។





# ជំពូក ៦
# ការផ្តល់ចំណីនិងទឹកដល់មាន់

## ១ .ការផ្តល់ចំណីដល់មេ បា និងមាន់ធំ

ត្រូវផ្តល់ចំណីឱ្យមាន់បាន២-៣ដងក្នុងមួយថ្ងៃ ដោយលាយបញ្ចូលគ្នារវាងចំណីបាវ (ផ្សំស្រេច) ៥០% និងចំណីដែលមានក្នុងភូមិ ៥០% (ដូចជា៖ កន្ទក់ ចុងអង្ករ ស្រូវ ត្រកួន បន្លែបៃតងជាដើម)។ ចំពោះត្រកួន និង បន្លែត្រូវហាន់ឲ្យល្អិតៗ ។




លាយចំណីជាមួយបន្លែ (ចេក ស្មៅត្រកួន...) និងការផ្តល់ឱ្យមាន់ស៊ី

## ២. ការផ្តល់ចំណីដល់កូនមាន់

ដើម្បីបង្កើនអត្រារស់របស់កូនមាន់ និងមាន់កំពុងលូតលាស់ ចាំបាច់ត្រូវប្រើចំណីគ្រាប់ ។ ត្រូវផ្តល់ចំណីបាវគ្រាប់ល្អិត (ផ្សំស្រេច) ដល់កូនមាន់រហូតដល់អាយុក្រោម ១ខែ ឱ្យបានច្រើនដង (៤-៥ដង) ក្នុងមួយថ្ងៃ ។ ពេលអាយុជិត ១ខែ ត្រូវលាយបន្ថែមជាមួយចុងអង្ករ និង កន្ទក់ម៉ត់លេខ១។



*ការផ្តល់ចំណីមានគុណភាព ធ្វើឲ្យអត្រារស់របស់កូនមាន់ខ្ពស់*

## របៀបលាយចំណីកូនមាន់៖

កូនមាន់អាយុក្រោម ៣អាទិត្យ ត្រូវផ្តល់ចំណីផ្សំស្រេចសុទ្ធ ហើយបន្ទាប់ពីនេះត្រូវលាយចំណីផ្សំស្រេចជាមួយចុងអង្ករ ពោត... ដែលកិនល្អិតៗ ដើម្បីឱ្យកូនមាន់ងាយស្រួលលេបចូល ។ ជាដំបូងត្រូវលាយចំណីដែលមានក្នុងភូមិប្រហែល ២០% និងអាទិត្យបន្ទាប់ប្រហែល ៣០%។





*ការផ្តល់ចំណីមានគុណភាព ធ្វើឱ្យអត្រារស់របស់កូនមាន់ខ្ពស់*

## ៣. ការផ្តល់ទឹក

មាន់ត្រូវការទឹកផឹកគ្រប់ពេលវេលា ដើម្បីការលូតលាស់ និងផលិតកម្មពង ។ មាន់អាចស្លាប់ប្រសិនបើគ្មានទឹកផឹករយៈពេល ២៤ ម៉ោង ។

**ត្រូវផ្តល់ទឹកស្អាតជានិច្ច និងគ្រប់ពេល ៖**

- មាន់ពង១០ក្បាល ត្រូវការទឹក ៥ លីត្រក្នុងមួយថ្ងៃ
- មាន់សាច់ ៥០ ក្បាល (១ក្បាលទម្ងន់ ១គក្រ) ត្រូវការទឹក ១០លីត្រ ក្នុងមួយថ្ងៃ
- កូនមាន់ត្រូវការទឹកជាប្រចាំ



*ការផ្តល់ទឹកស្អាតដល់មាន់*





# ជំពូក ៧
# ជីវសុវត្ថិភាព និងការធ្វើអនាម័យ

សុខភាពមាន់ គឺជាគន្លឹះដ៏សំខាន់សម្រាប់ការចិញ្ចឹម ។ កសិករស្ទើរតែទាំងអស់មានការខាតបង់ ដោយសារការផ្ទុះឡើងនូវជម្ងឺឆ្លង កាចសាហាវ ដែលសំលាប់មាន់ ស្ទើរគ្មានសល់ក្នុងមួយឆ្នាំៗ។

- ជម្ងឺបង្កឡើងដោយវីរុស គ្មានថ្នាំព្យាបាលទេ
- ជម្ងឺបណ្តាលមកពីបាក់តេរី អាចព្យាបាលបានខ្លះ ដោយប្រើថ្នាំអង់ទីប៊ីយូទិក
- ជម្ងឺបណ្តាលមកពីបរាសិត (ព្រូន អង្កែ...) ព្យាបាលដោយថ្នាំទំលាក់ព្រូន ឬ សម្លាប់អង្កែ។ មាន់អាចចម្លងជម្ងឺយ៉ាងរហ័សពីមួយទៅមួយ តាមរយៈកាកសំណល់ លាមក ទឹកសំបោរ ។ ជួនកាល អ្នកចិញ្ចឹមមិនអាចមើលដឹងថា មាន់ណាមួយមានផ្ទុកជម្ងឺឡើយ។

## ១. អនាម័យកន្លែងចិញ្ចឹម

- សំអាតព្រៃជុំវិញកន្លែង (ទ្រុង) ចិញ្ចឹម
- លប់ដីគ្រលុកដក់ទឹកឱ្យបានស្អាតល្អ
- ត្រូវក្រាលបាតទ្រុងជាមួយអង្កាម ឬ កំទេចអាចម៍រណារ
- ក្នុងកន្លែងមាន់ដេក (ទ្រុង) ត្រូវបោសសំអាតកើបលាមកមាន់ចេញរាល់ថ្ងៃ
- ត្រូវសម្លាប់មេរោគ និង បរាសិត (ក្នុងទ្រុង និងទីធ្លាចិញ្ចឹម) រៀងរាល់មុនពេលដាក់មាន់ យ៉ាងតិច ១ អាទិត្យ ដោយបាចកំបោរសដើម្បីកុំឱ្យមាន់ឆ្លងមេរោគ។



## ២. អនាម័យចំណីអាហារ និងទឹក

- មិនត្រូវយកទឹកកខ្វក់មកឱ្យមាន់ផឹកទេ។ ត្រូវផ្លាស់ប្តូរទឹកថ្មីមួយដងក្នុងមួយថ្ងៃ
- ចំណីដុះផ្សិត ផ្អូម មិនត្រូវផ្តល់ឱ្យមាន់ស៊ីទេ

## ៣. ការរៀបចំចិញ្ចឹមមាន់

- ត្រូវរៀបចំដាក់តាមប្រភេទ និងជំនាន់ (អាយុ) របស់វា (ក្រុមមេបា ក្រុមកូនជំទង់ និងក្រុមកូនតូចៗ ជាដើម)
- មាន់ទិញ ឬយកមាន់ចូលថ្មី ត្រូវរក្សាទុកវាដោយឡែកដាច់ពីគេចំនួន ១៤ ថ្ងៃ ។ បន្ទាប់



*ការសម្លាប់មេរោគដោយបាចទឹកកំបោរខាងក្រៅ និងក្នុងទ្រុងមាន់មុនពេលបញ្ចូលមាន់*



*ការរក្សាមាន់ទុក ដើម្បីតាមដានសុខភាពមុនដាក់បញ្ចូល*

មក បើសិនវាមានសុខភាពល្អ ទើបដាក់ចូលជាមួយមាន់ចាស់បាន ។

## ៤. អនាម័យលើការឆ្លងពីក្រៅ និងឧបករណ៍ចិញ្ចឹម

- មុនពេលចូលក្នុងទ្រុងមាន់ ត្រូវសម្លាប់មេរោគពិសេសដោយទឹកកំបោរជ្រលក់ស្បែកជើង ដែលមានដាក់នៅមាត់ច្រកចូល ជាមុនសិន។
- ហាមមិនឱ្យមនុស្សពីក្រៅ (អ្នកដើរទិញមាន់ អ្នកចិញ្ចឹមកន្លែងផ្សេង) ចូលក្នុងកន្លែងចិញ្ចឹមមាន់
- ស្អុកទឹក ស្អុកចំណីត្រូវឧស្សាហ៍លាងសំអាតជារៀងរាល់ថ្ងៃ
- ប្រសិនបើមាន់ងាប់ ត្រូវកប់ ឬ ដុតចោល ។ មិនត្រូវបោះវាចោល ពាសវាលពាសកាលនោះទេ ។
- មិនត្រូវបរិភោគមាន់ដែលងាប់ដោយសារជម្ងឺទេ ។






ដាក់ទឹកកំបោរថ្មនៅមាត់ច្រកចូលដើម្បីសំអាតបាតស្បែកជើង មុនពេលចូលក្នុងទ្រុងមាន់





ការកប់ ឬដុតបំផ្លាញចោល មាន់ដែលងាប់ ដោយសារជម្ងឺ





# ជំពូក ៨
# ការការពារជម្ងឺមាន់

ជម្ងឺមាន់ ជាជម្ងឺកាចសាហាវ មានការរាលដាលខ្លាំង និងបណ្ដាលឱ្យមាន់ស្លាប់ច្រើន ។ ហើយជម្ងឺភាគច្រើនជាជម្ងឺ មិនអាចព្យាបាលបាន ដូច្នេះវិធីដែលល្អប្រសើរបំផុត គឺការចាក់ថ្នាំបង្ការការពារ (វ៉ាក់សាំង)ជាមុន ។

## ១. ស្ថានភាពសុខភាព

### ១.១ មាន់ដែលមានសុខភាពល្អ

- សាច់ដុំទ្រូងលូតលាស់ល្អ រោមភ្លឺរលោង
- ជួនកាលវាមានសភាពស្គម តែវាមានសុខភាពល្អ ដែលបណ្ដាលមកសាច់មានពីការលូតលាស់មិនល្អ



*មាន់ដែលមានសុខភាពល្អ*



*មាន់មានសភាពស្គម តែវាមានសុខភាពល្អ រោមភ្លឺ*

### ១.២ មាន់ដែលមានសុខភាពមិនល្អ

- មានភាពស្គាំងស្គម រោមស្រអាប់
- អាចបណ្ដាលមកពីការផ្ដល់ចំណីមិនបានគ្រប់គ្រាន់
- ដោយសារជម្ងឺរ៉ាំរ៉ៃ ដូចជាព្រូន កុកស៊ីដ្យា ។



*មាន់ស្គមកំព្រឹង មិនស៊ីចំណី*

## ២. លក្ខណៈរបស់មាន់

### ២.១ លក្ខណៈធម្មតា

- ក្បាល និងកន្ទុយមានសភាពងើបឡើង
- ឈរត្រង់ ដំណើរក្លៀវក្លា រៀងវៃ
- ពេលផ្ដល់ចំណីបន្ថែម មាន់រត់លឿន និងចឹកចំណីស៊ីលឿន
- មិនមានបញ្ហាជើង
- សិរ និងណង់ មានពណ៌ផ្កាឈូកស្រស់ថ្លា
- ភ្នែកមានពន្លឺ មិនស្រអាប់
- រន្ធច្រមុះស្អាត គ្មានសំបោរ និងដង្ហើមគ្មានឮសម្លេង
- លាមកមានសភាពរឹង ពណ៌ប្រផេះត្នោត និងមានពណ៌សនៅពីលើ

### ២.២ លក្ខណៈមិនធម្មតា

- សំកុក ដេកផ្ដុំគ្នា
- មាន់មានសភាពស្ពឹកស្រពន់ មិនស៊ីចំណី បិទភ្នែក

- ក្អក កណ្តាស ដង្ហើមញាប់ (ដង្ហក់)
- នៅដាច់ពីគេ ដេកក្រោមម្លប់
- មានបញ្ហាជើង ស្លាបមិនកំរើក (ជាញឹកញាប់ ជារោគសញ្ញានៃជម្ងឺផ្លូង)
- មានពណ៌ក្រហមជាំនៅក្បាល និងសិរ
- ហូរទឹកចេញពីមាត់ និងច្រមុះ
- លាមកមានពណ៌ស ប្រផេះ លឿង ឬបៃតង
- លាមកមានឈាម មានព្រូន



ភ្នែក និងសិរមានសភាពភ្លឺ



ក្បាល និងកន្ទុយងើបឡើង បង្ហាញថា មាន់មានសុខភាពល្អ



មាន់មានបញ្ហាផ្លូវដង្ហើម



លាមកធម្មតា



ភ្នែកបិទ រោមបះ បង្ហាញថាមាន់មានជម្ងឺ



លាមកពណ៌ស (ជម្ងឺហ្គំបូរ៉ូ)



*លាមកលាយឈាម (ជម្ងឺកុកស៊ីដ្យូស៊ីស)*



*លាមកពណ៌បៃតង (ជម្ងឺអាសន្នរោគ)*

## ៣. ជម្ងឺដែលច្រើនកើតមានលើមាន់

ជម្ងឺជាច្រើនដែលបង្កឲ្យមានស្លាប់ស្រួចស្រាវ មានន័យថាមុនមួយថ្ងៃមាន់មានសុខភាពធម្មតា ហើយព្រឹកឡើងថ្ងៃបន្ទាប់វាក៏ស្លាប់ ។ ជាញឹកញាប់ជម្ងឺទាំងនេះធ្វើការសាយភាយនៅក្នុងហ្វូងយ៉ាងលឿន ដែលគេហៅថាការផ្ទុះជម្ងឺ ។

មាន់ស្លាប់យ៉ាងរហ័សដោយមិនបញ្ចេញរោគសញ្ញា ឬស្លាកស្នាមច្បាស់លាស់ ដែលជាហេតុធ្វើឲ្យមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យ ។

ជម្ងឺញ៉ូវកាស្ត ហ៊ុំបូរ៉ូ អាសន្នរោគ ផ្តាសាយបក្សី អាចបណ្តាលឲ្យមានការស្លាប់ស្រួចស្រាវ ។

### ៣.១ ជម្ងឺផ្លូវដង្ហើម

រាល់ជម្ងឺផ្លូវដង្ហើមទាំងអស់ តែងតែមានរោគសញ្ញាដូចគ្នា ដូចជា ៖

- ពិបាកដកដង្ហើម (មាន់ប្រឹងដកក)
- មានទឹកហូរចេញពីភ្នែក និងច្រមុះ
- កណ្តាស
- ហើមឆ្អឹងរន្ធច្រមុះ
- អត្រាស្លាប់ខ្ពស់



*មាន់ហើមភ្នែក ដោយមានទឹកហូរចេញ*

គេមានការលំបាកក្នុងការធ្វើរោគវិនិច្ឆ័យប្រៀបធៀបជាមួយជម្ងឺដទៃទៀត ។

**ជម្ងឺដែលបង្កដោយបាក់តេរី**

- កូរីហ្សា (Coryza)
- ជម្ងឺផ្លូវដង្ហើមរ៉ាំរ៉ៃ (CRD) ដូចជាមីកូប្លាស្មា
- ជម្ងឺអាសន្នរោគ

អង់ទីប៊ីយ៉ូទិកមានប្រសិទ្ធិភាពប្រឆាំងនឹងពួកវា។

**ជម្ងឺដែលបង្កដោយវីរុស**

- ជម្ងឺផ្តាសាយបក្សី
- ជម្ងឺញូកាស្ត (ND)
- ជម្ងឺរលាកទងសួត (IB)
- ជម្ងឺរលាកដើមក និងបំពង់ខ្យល់ (ILT)

អង់ទីប៊ីយ៉ូទិកមិនមានប្រសិទ្ធិភាពប្រឆាំងនឹងពួកវាទេ ។

### ក. ជម្ងឺផ្តាសាយបក្សី

ជាជម្ងឺដែលមានអត្រាស្លាប់ខ្ពស់ និងលឿន ។

រោគសញ្ញានៃជម្ងឺផ្តាសាយបក្សីមាន ៖

- ពិបាកដកដង្ហើម
- ខ្ជិន ញ៉ីរក្បាល
- ហើម/ជាំឈាមនៅសិរ និងណង់
- ជាំឈាមនៅជើង
- មិនស៊ីចំណី/សំកុក/រោមបះ



*រោមបះ និងសំកុក (រោគសញ្ញាដំបូង)*



*ជាំឈាមនៅជើង*



*ស្នាកស្នាមនៅក្បាល*

### វិធានការជីវសុវត្ថិភាព

ជីវសុវត្ថិភាព គឺជាការទប់ស្កាត់ការឆ្លងរាលដាលនៃជម្ងឺ ។ ជីវសុវត្ថិភាពជាមូលដ្ឋានរួមមាន ៖

- សង់ទ្រុងមាន់ឲ្យដាច់ពីផ្ទះ និងឆ្ងាយពីកន្លែងក្រខ្វក់
- ធ្វើរបងព័ទ្ធជុំវិញកន្លែងចិញ្ចឹមមាន់
- ទិញមាន់ពីកន្លែងដែលស្គាល់ប្រភពច្បាស់លាស់
- ផ្តល់ចំណី និងទឹកស្អាតឲ្យមាន់
- ដាក់មាន់ដែលយកមកថ្មីឲ្យនៅដោយឡែករយៈពេល ១៤ថ្ងៃ
- សំអាតផ្ទះ និងបរិវេណជុំវិញជាប្រចាំ
- ដាក់មាន់ឈឺនៅដាច់ដោយឡែកពីមាន់ជា
- យកមាន់ដែលស្លាប់ដោយជម្ងឺទៅកប់ ឬដុតចោល
- ក្រោយពេលមានមាន់ឈឺ ឬស្លាប់ ត្រូវសំអាតទ្រុង និងសម្ភារៈប្រើប្រាស់
- បំផ្លាញជម្រកសត្វកកេរ និងសត្វចង្រៃផ្សេងទៀតដែលមាននៅកន្លែងចិញ្ចឹម

## ខ. ជម្ងឺញ៉ូខាស

### រោគសញ្ញា

- ក្អក ដង្ហក់ កណ្តាស
- ខ្វិន ញាក់ញ័រ ធ្លាក់ស្លាប រមួលក
- ការជ្រៀតចូលពួកបាក់តេរីផ្សេងទៀត នឹងរឹតតែធ្វើឲ្យបញ្ហាផ្លូវដង្ហើមកាន់តែធ្ងន់ធ្ងរឡើង ។

### ការចម្លងដោយផ្ទាល់

- តាមលាមក និងទឹកសំបោរ



*មាន់ក្អក ដង្ហក់*

### ការចម្លងដោយប្រយោល

- តាមចំណី ទឹក សម្ភារៈ និងសំលៀកបំពាក់
- ចរាចរមាន់ដែលមានមេរោគ និងមនុស្ស ជាប្រភពចំបងក្នុងការសាយភាយជម្ងឺ



*ទីផ្សារមាន់រស់ ជាកន្លែងសាយភាយវីរុសញ៉ូកាស*

### ស្លាកស្នាម

- ស្ទុះ និងមានខ្ទុះនៅផ្លូវដង្ហើម
- ចង់ខ្យល់មានសភាពស្រអាប់ និងក្រាស់
- ដំបៅរលួយមានខ្ទុះនៅប្រអប់មាត់
- ហូរឈាមនៅបំពង់ខ្យល់
- ហើមក
- ហូរឈាមនៅភ្នាសសើមនៃកែវភ្នែក



*ដំបៅរលួយមានខ្ទុះ*



*ស្នាមហូរឈាមនៅបំពង់ខ្យល់*



*ស្នាមហូរឈាមនៅភ្នាសសើមនៃកែវភ្នែក*

### ការព្យាបាល

គ្មានការព្យាបាលទេ ព្រោះវាបង្កឡើងដោយវីរុស ។

### ការការពារ

- ប្រើវ៉ាក់សាំង អាយធូ (I2) បន្តក់តាមភ្នែក
- ត្រូវបន្តក់វ៉ាក់សាំងនៅពេលមាន់មានអាយុ ១ ថ្ងៃ និង៣សប្តាហ៍ (អាចការពារបាន ក្នុងរយៈពេល ៦ខែជាង) ។



*ការបន្តក់វ៉ាក់សាំង អាយធូ (I2)*

### វិធានការជីវសុវត្ថិភាព

- ការក្រុងមាន់ គឺជាវិធានការដ៏ល្អក្នុងការការពារការសាយភាយជម្ងឺញ៉ូកាស្ត
- ដាក់មាន់ដែលយកមកថ្មីឲ្យនៅដោយឡែករយៈពេល ២សប្តាហ៍ ដើម្បីការពារកុំឲ្យពួកវាបញ្ចេញមេរោគចម្លងដល់គេ ក្នុងកំឡុងពេលដែលមេរោគសម្ងំ

- ក្នុងកំឡុងពេលក្រុងនេះ ចាំបាច់ត្រូវតាម ដានសុខភាពមាន់ជាប្រចាំ
- បន្ទាប់ពី ២សប្តាហ៍ បើមាន់មានសុខភាពល្អ អាចព្រលែងវាទៅក្នុងហ្វូងបាន



*ការក្រុងមាន់ថ្មីរយៈពេល ២សប្តាហ៍*

### គ. ជម្ងឺរលាកទងសួត

**រោគសញ្ញា**

- ក្អក
- កណ្តាស
- ដកដង្ហើមមានឮសូរក្រិកៗរណ្តំគ្នា
- ផលិតកម្មស៊ុតថយចុះ រួមជាមួយនឹងស៊ុតមានគុណភាពអន់ ។ ជាទូទៅស៊ុតមានទម្រង់មិនប្រក្រតី សំបកស្តើង ហើយផ្នែកសនៃស៊ុតមានសភាពរាវ ។

ជម្ងឺរលាកទងសួតមានសភាពឆ្លងរាតត្បាតខ្លាំង ដោយធ្វើការចម្លងតាមខ្យល់ តាមសត្វដែលស្លាប់ និងតាមសត្វកកេរ ។



*ទម្រង់ស៊ុតដែលមាន់មានជម្ងឺ រលាកទងសួត*

### ឃ. ជម្ងឺរលាកបំពង់សម្លេង និងបំពង់ខ្យល់

**រោគសញ្ញា**

- ថប់ដង្ហើមយ៉ាងខ្លាំង
- ក្អក
- ដកចង្កាមាន់
- ចំពុះមានឈាម និងស្លេសដែលហូរចេញពីបំពង់ខ្យល់ ជាពិសេសនៅពេលក្អក



*បំពង់ខ្យល់មានសុទ្ធតែឈាម*

### ខ. ជម្ងឺគូរីហ្សា (Coryza)

ជាជម្ងឺបង្កឡើងដោយបាក់តេរី ។

**រោគសញ្ញា**

- មានហូរសំបោរខ្លាំងចេញពីរន្ធច្រមុះ និងកណ្តាស
- ជូនហើមមុខ
- មិនឃើញមានរោគសញ្ញាផ្លូវដង្ហើមធ្ងន់ធ្ងរ
- សត្វមានអាយុកាន់តែច្រើន កាន់តែងាយទទួលជម្ងឺ ។

**ការចម្លង**

- គឺការប៉ះពាល់ផ្ទាល់រវាងសត្វឈឺ និងសត្វជា
- ចរន្តខ្យល់បក់នាំមកជាមួយនូវធូលីដែលមានមេរោគ
- ផឹកទឹកដែលមានមេរោគ

**ការព្យាបាល**

- ប្រើអេរីត្រូមីស៊ីន (Erythromycin) និងអុកស៊ីតេត្រាស៊ីគ្លីន (Oxytetracycline) លាយក្នុងទឹកឲ្យសត្វផឹករយៈពេល ៥ថ្ងៃ



ហើមក្រោមភ្នែក

**ច. ជម្ងឺមីកូប្លាស្មា** ( Mycoplasma )

**រោគសញ្ញា**

- បញ្ហាដង្ហើមមានសភាពប្រែប្រួល
- ដកដង្ហើមឮសូរក្រិកៗ
- ក្អករន្ទើន ឬកណ្តាស
- អត្រាឈឺខ្ពស់ តែអត្រាស្លាប់ទាប



សត្វពិបាកដកដង្ហើម

**ស្លាកស្នាម**

- រលាករន្ធច្រមុះ
- រលាកបំពង់ខ្យល់
- រលាកថង់ខ្យល់

**ការព្យាបាល**

- មាន់ដែលឈឺដោយជម្ងឺនេះ តែងតែងាយរងទទួលនូវបាក់តេរី ឆ្លៀតឱកាសផ្សេងទៀត
- គ្រប់ប្រភេទពួកមីកូប្លាស្មា ប្រើត្រូវនឹងប្រភេទថ្នាំអេរីត្រូមីស៊ីន ( Erythromycin ) ក្លរតេត្រាស៊ីគ្លីន ( Chlortetracycline ) ទីឡូស៊ីន ( Ty-losine ) ឬអង់រ៉ូហ្លុកសាក់ស៊ីន ( Enrofloxa-cin ) ។ គេប្រើពួកវាដោយលាយជាមួយទឹកឲ្យផឹករយៈពេល ៧ថ្ងៃ ។




អេរីត្រូមីស៊ីន + អុកស៊ីតេត្រា ស៊ីគ្លីន ( OTC )
ជាប្រភេទថ្នាំ ដ៏ល្អសម្រាប់ព្យាបាលមីកូប្លាស្មា

**ការការពារ**

- ចំពោះកសិដ្ឋានពាក់កណ្តាលឧស្សាហកម្ម គេប្រើទីឡូស៊ីន + វីតាមីនសេ ( Tylosine + Vitamin C ) នៅពេលសត្វមកដល់ដំបូងដោយប្រើរយៈពេល ៧ថ្ងៃ ។

**ឆ. ជម្ងឺអាសន្នរោគ** ( Fowl Cholera )

បង្កឡើងដោយបាក់តេរីឈ្មោះ ប៉ាស្ទ័ររ៉ែលឡា ( Pasteurella ) វាច្រើនកើតឡើងដោយសាពួកមីកូប្លាស្មា បរាសិត កង្វះជីវជាតិ កង្វះអនាម័យ ។

**រោគសញ្ញា**

- ស្លាប់លឿន
- ហើមក្បាលណង់ ខ្វង់ច្រមុះ បាតជើង និងសរសៃពួរ

- លាមករាគពណ៌សលាយខៀវ និងធុំក្លិនស្អុយ
- ដង្ហក់
- មានហូរសំបោរចេញពីរន្ធច្រមុះ និងមាត់

**ការពារ**

- ប៉ាស្ទ័ររ៉ែលឡាអាចរស់ក្នុងមជ្ឈដ្ឋានសើមបានយូរថ្ងៃ (សម្រាម ភក់ជ្រាំ កន្លែងក្រខ្វក់)



ណង់ហើម

- វាអាចរស់នៅបានយូរខែក្នុងសាកសពដែលរលួយ និងសើម
- តែវាងាយងាប់នៅពេលត្រូវពន្លឺព្រះអាទិត្យ



នេះជាមជ្ឈដ្ឋានល្អសម្រាប់មេរោគលូតលាស់

កំដៅសម្ងួត ។ ដូចនេះការសម្អាត និង សម្ងួតនៅមជ្ឈដ្ឋានជុំវិញ អាចការពារជម្ងឺនេះបាន ។

មជ្ឈដ្ឋានល្អ គឺជាវិធានការដ៏ល្អក្នុងការការពារជម្ងឺអាសន្នរោគ ។

នេះជាមជ្ឈដ្ឋានល្អសម្រាប់មេរោគលូតលាស់

**ការព្យាបាល**

- ចាក់អុកស៊ីតេត្រាស៊ីគ្លីន (OTC) ៥០មក្រ/ក្បាល
- លាយតេត្រាស៊ីគ្លីនក្នុងចំណីឲ្យមាន់ស៊ីរយៈពេល ៣០ថ្ងៃ ព្រោះបាក់តេរីប៉ាស្ទ័ររ៉ែលឡាអាចរស់នៅក្នុងទឹក និងដីបានដល់ទៅ ៣សប្តាហ៍ ។
- ដើម្បីចៀសវាងកុំឲ្យមេរោគឆ្លងទៅក្នុងទឹក និងដី នៅពេលមានមាន់ស្លាប់ ចាំបាច់ត្រូវដុតសាកសពចោល ។



ចាក់អុកស៊ីតេត្រាស៊ីគ្លីន (OTC) តាមសាច់ដុំទ្រូង

ចាក់អុកស៊ីតេត្រាស៊ីគ្លីន(OTC) តាមសាច់ដុំទ្រូង

### ៣.២ ជម្ងឺរលាកពោះវៀន

ជម្ងឺរលាកពោះវៀន តែងតែមានរោគសញ្ញាដូចជា ៖

- រាគ
- រោមនៅជុំវិញក្លូអាក់មានសភាពក្រខ្វក់
- ស្រេកទឹក / ខ្សោះទឹក
- សត្វស្គមលឿន

ការពិនិត្យលាមក និងការវះកាត់សាកសព អាចជាជំនួយក្នុងការធ្វើរោគវិនិច្ឆ័យ ។

ជម្ងឺរលាកពោះវៀន អាចបង្កឡើងដោយ ៖

- ❖ បារាសិត ដូចជាអាស្ការី (Ascaridia) កុកស៊ីដ្យា (Coccidia)
- ❖ បាក់តេរី ដូចជាជម្ងឺបង្កឡើងដោយអ៊ីកូលី (E. coli) សាល់ម៉ូណែលឡា (Salmonella)
- ❖ វីរុស ដូចជាជម្ងឺហ្គំបូរ៉ូ (Gumboro)
- ❖ កត្តាផ្សេងៗ
- ❖ ព្រូនមូល (Ascarisa) និងតេញ៉ា

**រោគសញ្ញា**

- ❖ លូតលាស់យឺត ស៊ុតតិច ហើយសត្វងាយទទួលជម្ងឺ ។

**ការព្យាបាល និងការការពារ**

- ❖ ប្រើតេត្រាមីសូល (Tetramisole) ១០០មក្រ ក្នុងមាន់ទម្ងន់ ២គក្រ
- ❖ ឬពីប៉េរ៉ាស៊ីន (Piperazine) ឬឡេវ៉ាមីសូល (Levamisole)



*ព្រូនក្នុងលាមក*

**ក. កុកស៊ីដ្យូស៊ីស** (Coccidosis)

បង្កឡើងដោយប្រូតូសូអា ប្រភេទអេមេរ៉ា (Eimeria)។

**រោគសញ្ញា**

- ❖ កើតមានលើកូនមាន់
- ❖ ស្គមកំព្រឹង
- ❖ ស្រេកទឹក
- ❖ ស្លឹកស្រពន់
- ❖ រោមបះ
- ❖ លាមកអាចមានឈាម ដោយសារមេរោគធ្វើឲ្យដាច់ពោះវៀន
- ❖ ក្នុងករណីធ្ងន់ធ្ងរលាមកមានពពុះ មានឈាម



*លាមកមានឈាម*

**ការព្យាបាល**

- ❖ ប្រើស៊ុលហ្វា ៣៣ (Sulfadimerazine) លាយក្នុងទឹកឲ្យផឹកចំនួន ៣ថ្ងៃ ក្នុងកំរិត ១០ មល ក្នុងទឹក ១លីត្រ
- ❖ ឬស៊ុលហ្វាឌីមីឌីន (Sulfadimidine) អំប្រូលីយ៉ូម (Amprolium)

**ការការពារ**

- ❖ អនាម័យជាប្រចាំ
- ❖ កម្រាលត្រូវស្ងួតល្អ (ពិសេសស្នូកទឹក ស្នូកចំណី)



### ខ. កូលីបាក់ស៊ីឡូស៊ីល (Colibacillosis)

បង្កឡើងដោយអឺកូលី (E. Coli)។

**រោគសញ្ញា**

- អឺកូលីបំបែកខ្លួននៅក្នុងពោះវៀន តែរោគសញ្ញាដែលលេចចេញដំបូង គឺផ្លូវដង្ហើម ព្រោះបាក់តេរីអឺកូលីសាយភាយចូលទៅក្នុងថង់ខ្យល់
- មាន់ស្លឹកស្រពន់ រោមបះ ប្រឹងដកដង្ហើម ក្អក ដកដង្ហើមឮសូរ
- រាគដោយសាររលាកពោះវៀន



*រោមបះ សញ្ញាផ្លូវដង្ហើម និងរាគ*

ត្រូវចាំថា អឺកូលីជាជម្ងឺឆ្លៀតឱកាស ដែលកើតឡើងក្រោយពីមានមីកូប្លាស្មា ។

**ស្លាកស្នាម**

- មានខ្ទុះខាប់នៅក្នុងថង់ខ្យល់ ស្រោមបេះដូង និង នៅលើផ្ទៃនៃបេះដូង ថ្លើម និងសួត

**ការព្យាបាល**



*ស្នាមរលាកសរសៃមានលើថ្លើម*

អង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin) ជាឱសថដែលមានប្រសិទ្ធិភាពប្រឆាំងនឹងបាក់តេរីទាំងពីរប្រភេទនេះ ។

### គ. សាល់ម៉ូណែលឡូស៊ីល (Salmonellosis)

សាល់ម៉ូណែលឡាមានច្រើនប្រភេទ ដូចជា ហ្គាលីណារ៉ូម (Gallinarum) ពុលឡូរ៉ូម (Pullorum) ... នៅពេលមានបញ្ហា ពោះវៀន គួរតែធ្វើរោគវិនិច្ឆ័យប្រៀបធៀបលើសាល់ម៉ូណែលឡា នេះ ។

**រោគសញ្ញា ( ប្រភេទ Pullorose )**

- កើតមានលើកូនមាន់អាយុតិចជាង ២សប្តាហ៍
- លាមករាគពណ៌សលឿង
- ក្លូអាក់ចំហរ ដោយសារលាមកស្អិតជាប់
- មាន់មិនស៊ីចំណី សំយ៉ុងក្បាលចុះក្រោម



*លាមកស្អិតជាប់នៅក្លូអាក់កូនមាន់*

**រោគសញ្ញា ( ប្រភេទ Typhose )**

- កើតមានលើមាន់ធំទង់
- មិនស៊ីចំណី សំកុក
- លាមករាគពីពណ៌លឿងទៅពណ៌ខៀវ មានឆ្នុតឈាម

**ការចម្លង**

- តាមរយៈស៊ុត ឬការប៉ះពាល់ផ្ទាល់ជាមួយសត្វដែលផ្ទុកជម្ងឺ

ស្លាកស្នាម

❖ ពុលឡ៉ូស មានដុំពកពណ៌ប្រផេះនៅលើថ្លើម ផាល សួត បេះដូង គោះ និងពោះវៀន

❖ ទូហ្វូស ថ្លើម និងផាលរីក ( មានពណ៌លឿង ) ផ្លូវអាហារគ្របដណ្តប់ដោយហ្វីប្រ៊ីន ( Fibrin )



ដុំពកពណ៌ប្រផេះនៅថ្លើម

**ការព្យាបាល**

❖ ប្រើអង់រ៉ូហ្លុកសាក់ស៊ីន (Enrofloxacin) ។ ករណីកើតមានលើមនុស្ស ច្រើនបណ្តាលមកពីការបរិភោគសាច់មាន់ដែលមិនបានចំអិនឲ្យបានឆ្អិនល្អ ។

**ឃ. ជម្ងឺហ្គំបូរ៉ូ** ( Gumboro )

ជម្ងឺនេះបង្កឡើងដោយវីរុស ។ ច្រើនកើតលើមាន់ដែលមានអាយុតិចជាង ១០សប្តាហ៍ ។

**រោគសញ្ញា ( ប្រភេទ Pullorose )**

❖ មានសភាពអស់កម្លាំងខ្លាំង មិនអាចបញ្ជាខ្លួនឯងបាន

❖ រាគទឹកពណ៌ស ប្រឡាក់ជាប់នៅរោមក្លូអាក់ មាន់ចឹកក្លូអាក់ និងរលាកក្លូអាក់

ស្លាកស្នាម

❖ ថង់ក្លូអាក់មានសភាពហើមពណ៌លឿង ហើយជួនកាលអាចមានឈាម

**ការព្យាបាល**

❖ គ្មានថ្នាំព្យាបាលទេ តែសត្វខ្លះអាចជា

❖ ចាក់វ៉ាក់សាំង

៣.៣.ជម្ងឺសរសៃប្រសាទ

ជម្ងឺនេះអាចបង្កឡើងដោយ ៖

❖ បាក់តេរី : បូទុយលីស ( Botulism )

❖ វីរុស : ញូវកាស ( Newcastle ) និងម៉ារិក ( Marek )

❖ សារធាតុគីមី : ជាតិពុល (ថ្នាំសម្លាប់សត្វល្អិត)

**រោគសញ្ញាប្រព័ន្ធប្រសាទ រួមមាន ៖**

❖ អស់កម្លាំង

❖ ខ្វិន / ពិការ

❖ ប្រកាច់តែរ៉ៃ

**ក. បូទុយលីស** ( Botulism )

វាបង្កឡើងដោយបាក់តេរីក្លូស្ទ្រីដ្យូម (Clostridi-um Botulimum ) ។ បាក់តេរីនេះរស់នៅក្នុងបំពង់អាហាររបស់មាន់ និងបក្សីព្រៃ ហើយបញ្ចេញទៅក្នុងសំបុកចំណី ទឹក ដែលមាននៅក្នុងទ្រុងមាន់ ។ បន្ទាប់ពីសត្វស្លាប់ បាក់តេរីបានបញ្ចេញជាតិពុល ។ ដង្កូវដែលមាន



រាគសលាយទឹក



កូនដង្កូវលើសាកសពរលួយ

នៅក្នុងសាកសពសត្វនេះ ពេញទៅដោយជាតិពុល ហើយនៅពេលដែលមាន់ស៊ីដង្កូវនេះ ធ្វើឲ្យវាកើតមានជម្ងឺ ។

**រោគសញ្ញា**

- ទន់ជើង ធ្លាក់ស្លាប ទន់ក និងធ្លាក់ត្របកភ្នែក
- ភាពទន់នេះនឹងផ្តើមពីជើងទៅស្លាប ក និង ត្របកភ្នែក ។

**ការការពារ**

- ប្រមូល និងកប់សាកសព ។

**ការព្យាបាល**

- មិនសូវមានប្រសិទ្ធិភាពទេ
- អាចប្រើប៉េង់ស្រ្តិប ( Pen-Strep )



*មាន់មានសភាពទន់*

**ខ. ជម្ងឺម៉ារ៉េក** ( Marek )

ជម្ងឺម៉ារេកបង្កឡើងដោយវីរុស គឺជាប្រភេទមហារីករបស់មាន់ ។

**រោគសញ្ញា**

- ខ្វិនជើង
- ជើងលាតសន្ធឹងទៅទិសផ្សេងគ្នា ជើងមួយសណ្តូកទៅមុខ ឯជើងមួយទៀត សណ្តូកទៅក្រោយ)



*ខ្វិនជើង*

**ស្លាកស្នាម**

- រីកសរសៃប្រសាទ ជាពិសេសសរសៃនៅផ្នែកខាងក្រោយជើង
- មានដុំពកនៅថ្លើម ផាល តម្រងនោម បេះដូង សួត សាច់ដុំ និងទងកោះ

**ការព្យាបាល**

- គ្មាន

**ការការពារ**

- ដោយចាក់វ៉ាក់សាំង





*សរសៃប្រសាទចង្កេះរីកធំ ជាហេតុធ្វើឲ្យខ្វិន*

## ៣.៨ ជម្ងឺលើស្បែក

ជម្ងឺនេះអាចបង្កឡើងដោយៈ

- បារាសិត : ចៃ ស្រមើរ ...
- វីរុស : អុតមាន់
- ការចឹកគ្នា : ទ្រុងចង្អៀត
- កង្វះវីតាមីន និងអាស៊ីដអាមីណេ

### ក. បរាសិតខាងក្រៅ

- បរាសិតខាងក្រៅដែលច្រើនកើតនោះ គឺចៃ
- ចៃបង្កឲ្យដាច់រលាត់ស្បែក
- មាន់នៅមិនស្ងៀមមិនសូវស៊ី ឬដេកមិនស្រួល

កត្តាទាំងនេះធ្វើឲ្យការលូតលាស់យឺត ពងបាន តិច និងងាយទទួលជម្ងឺ ។

**ការព្យាបាល**

ប្រើម៉ាឡាសុន ៥% ( Malathion 5% ) បាញ់ផ្ទាល់លើមាន់ ហើយរំលឹករៀងរាល់ ៣ខែម្តង ។ ម៉្យាងទៀតសំបុកក៏ត្រូវសំអាតដែរ។



*បរាសិតនៅរោមជុំវិញគូថអាក់*

### ខ. ជម្ងឺអុត

ជម្ងឺអុតបង្កឡើងដោយវីរុស ។

**រោគសញ្ញា**

- ស្លាកស្នាមដុំពកនៅត្រង់កន្លែងគ្មានរោម
- ទំហំរបស់ដុំពកនេះរីកធំយ៉ាងរហ័ស ហើយរួមបញ្ចូលគ្នាទៅជាទំហំធំពណ៌លឿង និងមានក្រម៉ក្រៀម
- ក្នុងទម្រង់ជាខាន់ស្លាក់ គេឃើញមានស្លាកស្នាមនៅក្នុងមាត់ បំពង់អាហារ និងបំពង់ខ្យល់ ដែលធ្វើឲ្យមានការពិបាកដកដង្ហើម ។



**ការចម្លង**

- កើតមានដោយសារការប៉ះផ្ទាល់ជាមួយស្បែកដែលដាច់
- ការខាំរបស់មូស និងសត្វល្អិតផ្សេងទៀត ក៏ជាការចម្លងជម្ងឺផងដែរ ។

**ការចាក់វ៉ាក់សាំង**

- គ្មានការព្យាបាលទេ តែជម្ងឺអុតមានការសាយភាយយឺត ដូចនេះការចាក់វ៉ាក់សាំងអាចបញ្ឈប់ការសាយភាយបាន
- ការចាក់វ៉ាក់សាំងការពារ ដោយការជួសស្លាប
- ចាក់នៅពេលមាន់មានអាយុចាប់ពី ១០ថ្ងៃ
- ត្រូវប្រយ័ត្ន វ៉ាក់សាំងអុតជាប្រភេទវ៉ាក់សាំងរស់ ហើយវាបង្កជាជម្ងឺក្នុងទម្រង់ស្រាល ដូចនេះត្រូវចាក់តែមាន់ណាដែលមានសុខភាពល្អ ។



### គ. ការចឹកគ្នា

ការចឹកគ្នា ចាប់ផ្ដើមនៅពេលមាន់មិនទាន់ដុះរោមពេញ ឬនៅពេលមានអាយុពី ២-៣សប្ដាហ៍ ។ សភាពបែបនេះបណ្ដាលឲ្យមានការចឹកគ្នាដ៏សាហាវ ពិសេសប្រសិនបើមានរបួស ។ មាន់អាចចឹកគ្នារហូតដល់ស្លាប់។

**មូលហេតុ**

- កង្វះអំបិលសារធាតុរ៉ែ និងដោយសារបរាសិតខាងក្នុង
- ទីកន្លែងចង្អៀតពេក



**ការការពារ**

- កាត់ចំពុះ
- ផ្ដល់ចំណីមានជាតិសរសៃខ្ពស់

### ឃ. កង្វះវីតាមីន

**កង្វះវីតាមីនអា :** ស្លាកស្នាមមាននៅលើភ្នែក គ្របកភ្នែកស្អិតជាប់គ្នា (វីតាមីនអាជួយបង្កើតភ្នាសសើម) ។

**កង្វះវីតាមីនដេ :** ធ្វើឲ្យមាន់ដែលមានរោមពណ៌ក្រហម និងត្នោត ក្លាយទៅជាខ្មៅ

**កង្វះវីតាមីនបេកំផ្លិច :** ឃើញមានក្រមំក្រៀមនៅជុំវិញភ្នែក និងចំពុះ ។ បាតជើងមានសភាពស្ងួតបែកក្រហែង និងក្រិនដោយមានឈាម ។



*កង្វះជីវជាតិចម្រុះ អាចឲ្យជម្ងឺងាយជ្រៀតចូល*

### ខ. កង្វះអាស៊ីដអាមីណេ

**កង្វះលីស៊ីន :** ធ្វើឲ្យអស់ពណ៌នៅរោមស្លាប ។

**កង្វះមេត្យូនីន :** រោមដុះមិនស្មើគ្នា រោមវែងខុសធម្មតា រោមមិនក្រាបរាបស្មើ ។



## ៤. លក្ខណៈទូទៅរបស់វ៉ាក់សាំង

វ៉ាក់សាំងសម្រាប់បង្ការការពារជម្ងឺ មិនមែនជាថ្នាំសម្រាប់ព្យាបាលទេ

- សត្វដែលអាចចាក់វ៉ាក់សាំងបាន គឺពេលដែលវាមានសុខភាពល្អ
- វ៉ាក់សាំង១មុខ អាចការពារជម្ងឺបានតែ ១មុខប៉ុណ្ណោះ
- ថ្នាំការពារខុសគ្នា មានវិធីប្រើខុសគ្នា (ផ្លូវបញ្ចូលថ្នាំ)
- ថ្នាំការពារជម្ងឺដូចគ្នាតែផលិតដោយក្រុមហ៊ុនខុសគ្នាក៏អាចមានវិធី ប្រើប្រាស់ខុសគ្នាដែរ។ ដូច្នេះគប្បីត្រូវដឹងឱ្យបានច្បាស់ពីវិធីប្រើប្រាស់ និងកំរិតប្រើប្រាស់វ៉ាក់សាំងនីមួយៗ ។
- វ៉ាក់សាំងដែលនៅសល់ពីការប្រើប្រាស់ត្រូវដុតចោល
- អ្នកត្រូវកត់ត្រា ថ្ងៃ ខែ និង ចំនួនមាន់ចាក់វ៉ាក់សាំង
- ត្រូវចាក់ថ្នាំការពារដល់មាន់ទាំងអស់ និងចាក់បានទៀងទាត់ ទើបមានប្រសិទ្ធិភាព។

### តារាងកម្មវិធីចាក់ថ្នាំការពារជម្ងឺមាន់

| អាយុ | ឈ្មោះវ៉ាក់សាំងការពារជម្ងឺ | ផ្លូវបញ្ចូល | រំលឹកឡើងវិញក្រោយចាក់ |
| --- | --- | --- | --- |
| ១-៣ ថ្ងៃ | ជម្ងឺដង្ហោកាច់ (ញ៉ូកាស I 2) | បន្តក់ក្នុងភ្នែក/ច្រមុះ | ៦ ខែ |
| ៧-១០ ថ្ងៃ | ជម្ងឺអុតមាន់ | ជួសស្បែកផ្ទាំងស្លាបរង | ១ ឆ្នាំ |
| ២ ខែ | ជម្ងឺអាសន្នរោគ | ចាក់សាច់ដុំ | ៦ ខែ |

**បញ្ជាក់:**

ក្នុងករណីមាន់ទុកសម្រាប់ធ្វើមេ និងបា ត្រូវចាក់រំលឹកឡើងវិញ ៥-៦ខែ ម្តង (ជម្ងឺញ៉ូកាស ជម្ងឺអាសន្នរោគ និងជម្ងឺរលាកផ្លូវដង្ហើម)

## កម្មវិធីទំលាក់ព្រូន

ទំលាក់ព្រូនលើកទី១ នៅពេលមាន់អាយុ ១ ខែ និងរំលឹកឡើងវិញ រយៈពេល ២ ទៅ ៣ ខែក្រោយមក ។ គេអាចប្រើថ្នាំ មេបង់ដាសុល សម្រាប់ទំលាក់ព្រូនមាន់ ។ ក្នុងថ្នាំ មេបង់ដាសុល ១ គ្រាប់ សម្រាប់ដាក់ឱ្យមាន់ទម្ងន់រស់សរុប ៥ គីឡូក្រាម។